មជ្ឈមណ្ឌលឯកសារកម្ពុជា

TKI0766

**សម្ភាសន៍ជាមួយឈ្មោះ ទឹម ភី ភេទស្រី អាយុ៥៥ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ ប្រធាននារីឃុំ**

**សព្វថ្ងៃរស់នៅភូមិចំបក់ ឃុំគោកព្រេច ស្រុកគីរីវង់ ខេត្តតាកែវ**

**ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០**

**សម្ភាសន៍ដោយៈ គីមស្រួយ សុខវិសាល និង សេង គន្ធី**

**០១:៤២:០២**

**៥១ទំព័រ**

វិសាល ៖ មុនដំបូងសុំជំរាបសួរអ្នកមីងណាបាទ! ហើយយើងទាំងអស់គ្នាហ្នឹងសុទ្ធតែជាបុគ្គលិករបស់មជ្ឈមណ្ឌលកសារកម្ពុជា មានខ្ញុំឈ្មោះគីមស្រួយ សុខវិសាល ហើយមានបងរ៉ាស៊ី មានបងសេងគា ហើយនឹងគន្ធី ។ ហើយដូចបានជម្រាបអ្នកមីងកាលពីម្សិលមិញចឹងថាយើងនេះចុះមកនេះ គឺចង់ដឹងពីប្រវត្តិសាស្រ្តដែលកើតឡើងចំពោះមីងដែលធ្លាប់បានឆ្លងកាត់មក ជាពិសេសគឺនៅសម័យខ្មែរក្រហម តើមានរឿងអីកើតឡើងខ្លះទៅដែលមីងបានឆ្លងកាត់ណាមីងណាបាទៗ ហើយចង់សុំសាច់រឿងដែលមីងមានប្រសាសន៍ហ្នឹងទុកសរសេរជាអត្ថបទ ឬក៏ប្រើប្រាស់ជាឯកសារប្រវត្តិសាស្រ្តអី មីងអនុញ្ញាតិទេមីង?

ភី ៖ មានអី តែរឿងហ្នឹងខ្ញុំវាមិនអាចចាំអស់ទេ ។

វិសាល ៖ បាទៗ ខ្ញុំយល់អត់អីទេអ្នកមីង បាទ! ។

ភី ៖ ខ្ញុំយល់ៗដឹងពីការស៊ីជម្រៅចំពោះខ្ញុំដែរណា ។

វិសាល ៖ បាទៗ ខ្ញុំមានសំនួរខ្លះសួរអ្នកមីង ហើយនៅពេលដែលអ្នកមីងមានប្រសាសន៍ចឹងទៅមកដល់ចំណុចណាដែលអ្នកមីងថាភ្លេចអីចឹង អត់អីទេមីង ៣០ឆ្នាំហើយអត់អីទេបាទ ។ អ្នកមីងមានប្រសាសន៍ត្រង់ចំណុចណាដែលអ្នកមីងចាំចុះ ហើយខ្ញុំនៅចាំសួរចាំស្តាប់ពីសាច់រឿងរបស់អ្នកមីងហាអ្នកមីងណា ។ បាទ! ចង់ជម្រាបសួរអ្នកមីងមានស្រុកកំណើតនៅៗភូមិនេះតែម្តង?

ភី ៖ ខ្ញុំនៅភូមិសំរោងកើត ។

វិសាល ៖ អូ! ស្រុកកំណើតនៅ...?

ភី ៖ នៅសំរោងកើត ។

វិសាល ៖ ភូមិ? ចុះឃុំអីដែរ?

ភី ៖ ឃុំគោកព្រិច ស្រុកគិរីវង់ ខេត្តតាកែវ ។

វិសាល ៖ ខេត្តតាកែវ បាទហើយថ្ងៃនេះថ្ងៃ ១៧ ខែកក្កដា ឆ្នាំ២០១០នេះ មីងនៅភូមិដដែល?

ភី ៖ ខ្ញុំនៅភូមិចំបក់ផលូវហ្នឹង ។

វិសាល ៖ អ៎! ភូមិហ្នឹងភូមិចំបក់ទេ ។

ភី ៖ ចា!

វិសាល ៖ ចុះឃុំអីដែរ?

ភី ៖ ឃុំគោកព្រេចហ្នឹង ។

វិសាល ៖ គោកព្រេច? ស្រុក?

ភី ៖ ស្រុកគិរីវង់ដដែលហ្នឹង ខេត្តតាកែវ ។

វិសាល ៖ បាទ! សព្វថ្ងៃអ្នកមីងមានអាយុប៉ុន្មានទៅហើយបាទអ្នកមីង?

ភី ៖ ៥៥ឆ្នាំ ។

វិសាល ៖ ៥៥ឆ្នាំបាទៗ ហើយឪពុកម្តាយអ្នកមីងគាត់នៅរស់ទេ ឬក៏...?

ភី ៖ ស្លាប់អស់ហើយ ។

វិសាល ៖ ស្លាប់ទាំងពីរនាក់តែម្តង?

ភី ៖ ចា!

វិសាល ៖ លោកឪពុកអ្នកមីងឈ្មោះអីដែរអ្នកមីង?

ភី ៖ ឈ្មោះ ទឹម អ៊ិន ។

វិសាល ៖ ទឹម អ៊ិន?

ភី ៖ ចា!

វិសាល ៖ គាត់ស្លាប់នៅពេលណាដែរ?

ភី ៖ ស្លាប់នៅប៉ុន្មានឆ្នាំហើយហ្នឹងនៅឆ្នាំ.....មើលឈប់នឹកមើលសិន ប្រហែល១៦-១៧ឆ្នាំហើយគាត់ស្លាប់ហ្នឹង ។

វិសាល ៖ ស្លាប់កាលរបបខ្មែរក្រហមទេ ។

ភី ៖ ចា!

វិសាល ៖ ចុះលោកយាយ?

ភី ៖ គាត់ ម្តាយខ្ញុំហ្នឹងស្លាប់ប្រហែលជា២-៣ឆ្នាំមុនហ្នឹង ។

វិសាល ៖ អ៊ឺ! បាទ អ្នកមីងមានបងប្អូនប៉ុន្មាននាក់ដែរ?

ភី ៖ បងប្អូន៧នាក់ ប៉ុនស្លាប់អស់ហើយនៅតែខ្ញុំ៣នាក់ទេឥលូវហ្នឹងនំ! ។

វិសាល ៖ នៅ៣នាក់? ពីណាខ្លះអាចជួយរៀបរាប់ឈ្មោះខ្លួនឯងក៏ដូចជាឈ្មោះបងប្អូនដែលនៅរស់បានទេមីង?

ភី ៖ តែខ្ញុំហ្នឹង ហើយបងខ្ញុំហ្នឹងផលហ្នឹង ហើយមួយហ្នឹងនៅកោះធំណោះ មានប្ដីនៅកោះធំនំ! នៅ៣នាក់ហ្នឹងទេ ។

វិសាល ៖ ឈ្មោះពេញ ឈ្មោះអ្នកមីងឈ្មោះពេញឈ្មោះអីទៅអ្នកមីង?

ភី ៖ ឈ្មោះ ទឹម ភី ។

វិសាល ៖ ទឹម ភី មានឈ្មោះហៅក្រៅទេ?

ភី ៖ ពីដើមនៅពីតូចគេហៅដុំៗ ។

វិសាល ៖ ដុំៗ?

ភី ៖ ចា ដុំៗៗពីដើមក កាលនៅពីតូច ។

វិសាល ៖ ដល់ពេលម៉េចទៅអ្នកមីង?

ភី ៖ ដល់ពេលសម័យឥលូវហ្នឹងគេហៅ ហៅជាទូទៅហ្នឹងឈ្មោះភីហ្នឹង ។

វិសាល ៖ ភី បាទ! ហើយគ្រួសារអ្នកមីងនៅជុំគ្នាទេ?

ភី ៖ នៅជុំគ្នា ។

វិសាល ៖ គាត់ឈ្មោះអីទៅ ប្ដីអ្នកមីង?

ភី ៖ ឈ្មោះទុំ ម៉ែត ។

វិសាល ៖ ទុំ ម៉ែត ហើយសព្វថ្ងៃគាត់ប្រកបមុខរបរអីដែរ?

ភី ៖ ធ្វើស្រែ ។

វិសាល ៖ ធ្វើស្រែ ហើយអ្នកមីង?

ភី ៖ ធ្វើស្រែដូចគ្នាហ្នឹង ។

វិសាល ៖ ព្រុថាមានលក់ដូរអីតិចតួចដែរ?

ភី ៖ អឺម...តិចតួចហ្នឹងវាជាការបន្ទាប់បន្សំទេ វាគ្មានជាការជាអាជីពអីច្បាស់លាស់ទេ គ្រាន់តែជាការបន្ទាប់បន្សំបណ្ដោះអាសន្នហ្នឹង ។

វិសាល ៖ ហើយកូនៗមាន?

ភី ៖ កូន៧នាក់ ។

វិសាល ៖ ៧នាក់ ហើយនៅរស់ជុំអ្នកមីងប៉ុន្មាននាក់ ហើយនៅឆ្ងាយធ្វើការខាងក្រៅប៉ុន្មាននាក់ទៅ?

ភី ៖ មកនៅ កូននៅទាំងអស់មក១បួស កូនទី១បួស អាយុ៣០ជាងហើយ បួសមិនទាន់សឹកទេ ។

វិសាល ៖ អ៎! បួសបាទ ។

ភី ៖ អឺម! កូនទី២ប្រុសដែរ ។

វិសាល ៖ ប្រុសដែរ?

ភី ៖ នៅមានប្រពន្ធហើយនៅខេត្តភូមិដំបូកខ្ពស់ ខេត្តកំពតនោះ ។

វិសាល ៖ បាទកូនបន្ទាប់មកទៀតអ្នកមីង?

ភី ៖ កូនទី៣ហ្នឹងនៅហ្នឹង ។

វិសាល ៖ បាទ! កូនទី៣ស្រី?

ភី ៖ ស្រី!

វិសាល ៖ ដំបូងប្រុស២ បន្ទាប់មកទៀត?

ភី ៖ បន្ទាប់មកទៀតហ្នឹងមួយហ្នឹងស្រីដែរ វារៀនទៅហ្នឹង ប្រលងធ្លាក់វាទៅធ្វើខ្ញុំគេបាត់ហើយ ។

វិសាល ៖ បាទ! កូនស្រី២នាក់ សល់៣នាក់ទៀត កូន៧នាក់ អ៊ំនេះ?

ភី ៖ ចា៎! កូន៧នាក់ ហើយម្នាក់ទៀតនេះ មួយកើបស្រូវហ្នឹង ។

វិសាល ៖ អ៎! កូនស្រីដែរ?

ភី ៖ កូនស្រីដែរ ។

វិសាល ៖ បាទ!

ភី ៖ ហើយម្នាក់ទៀតហ្នឹងប្រុស! ជិះម៉ូតូទៅណាបាត់ហើយដើរលេងហ្នឹង ។

វិសាល ៖ បាទ! ហើយម្នាក់ទៀត?

ភី ៖ ម្នាក់ទៀត នៅធ្វើខ្ញុំគេអីប៉ោយប៉ែតនោះ ។

វិសាល ៖ អ៎! បាទប្រុសហើយស្រី?

ភី ៖ ស្រី ។

គន្ធី ៖ អូ! ស្រីបាទ! ប្រុស៣ស្រី៣?

ភី ៖ អឺ....ប្រុស៣ស្រី៤ ៧ ។

វិសាល ៖ បាទ! ចង់ត្រលប់ចង់សួរពេលមីងនៅតូចវិញម្តង បាទ! ពេលដែលមីងកើតដឹងក្តីឡើង ហ្នឹង ឃើញនៅភូមិហ្នឹងហ្នងឬក៏ម៉េច?

ភី ៖ កើតនៅភូមិណោះហ្នង ។

វិសាល ៖ បាទ! កាលហ្នឹងលោកតាលោកយាយហ្នឹងប្រកបមុខរបរអីដែរ?

ភី ៖ ធ្វើស្រែដែរ ។

វិសាល ៖ ធ្វើស្រែដែរ អ្នកមីងមានបានទៅរៀនសូត្រទៅអីទេ?

ភី ៖ រៀន ។

វិសាល ៖ រៀន?

ភី ៖ ចា! បានរៀនដែរហ្នឹង ។

វិសាល ៖ រៀននៅត្រង់ណាដែរអ្នកមីង?

ភី ៖ រៀននៅសាលាវត្តព្រៃដើងហ្នឹង ។

វិសាល ៖ ព្រៃដើង រៀនដល់ថ្នាក់ទីប៉ុន្មានទៅអ្នកមីង?

ភី ៖ ចប់ថ្នាក់ទី៨ហើយ ។

វិសាល ៖ ចប់ថ្នាក់ទី៨?

ភី ៖ ចា!

វិសាល ៖ កាលហ្នឹងចេះអានចេះសរសេរហើយ?

ភី ៖ ចេះតើ ។

វិសាល ៖ អ៎! ចេះអានចេះសរសេរហើយ ។

ភី ៖ រៀនអក្សរបារាំងអីចេះបានតិចតួចដែរ ។

វិសាល ៖ បានដែរ! អានដាច់អីទេមីង ចេះបារាំងអីចេះអានមើលយល់អីទេ?

ភី ៖ បើថាទៅអីចឹងទៅ បើថាទៅអីចឹងទៅបើថាប្រែអីចឹងទៅខ្ញុំមិនដឹងទេ បើថាគេដាក់ផ្លាក អីចឹងទៅអក្សរបារាំងអីហ្នឹងគ្រាន់តែអាចមើលបានតែបើអង់គ្លេសមិនចេះសោះ ។

វិសាល ៖ អត់ចេះ ដូចថាឈ្មោះថ្នាំអីចឹងហាចេះមើលទេ?

ភី ៖ បើអាណាស្រណុកៗអីចេះមើលបានដែរហ្នឹង ។ បើថាដូចថាវាគ្មានអក្សរធំទេហា! អក្សរ បារាំងវាមិនមានអាពាផ្អែក ។

វិសាល ៖ បាទ! អក្សរពុម្ពដៃធំ ។

ភី ៖ អាហ្នឹងមើលមិនបានទេ បើថាដូចអក្សររាយៗអីចឹងចេះមើលបានហើយ ។

វិសាល ៖ បាទ! មីងមានប្រសាសន៍ថារៀននៅថ្នាក់ទី៨...?

ភី ៖ ចា!

វិសាល ៖ ហើយដល់ចប់ថ្នាក់ទី៨ហ្នឹងម៉េចទៅមីង ឬក៏ឈប់មីង?

ភី ៖ ទី៨ហ្នឹងរដ្ឋប្រហារហ្នឹង ចឹងទៅមានបានរៀនអីទៀត។

វិសាល ៖ អ៎! រដ្ឋប្រហារឆ្នាំ៧០មីងឈប់រៀន?

ភី ៖ ចា!

វិសាល ៖ ឈប់ដោយសារកាលហ្នឹងឈប់ដោយសារសាលាអត់មានគ្រូឬក៏ទម្លាក់គ្រាប់បែក?

ភី ៖ គ្រូអត់មានអីទេ មានស្អី អត់មានទេហ្នឹង ហើយបើគេចង់បង្រៀនហ្នឹងទៅៗគឺរី(រង់) យើងដូចថាគ្មានសមត្ថិភាព យើងទៅមិនទៅរួចឈប់ទៅ។

វិសាល ៖ ចុះបងប្អូនផ្សេងទៀត មានបានរៀនដូចអ្នកមីងទេឬក៏អត់ទេ?

ភី ៖ រៀនទាំងអស់ តែរៀនបានត្រឹមប៉ុណ្ណឹងៗទាំងអស់ហ្នឹង បានភាគច្រើនតិចជាងខ្ញុំ។

វិសាល ៖ ចឹងមីងរៀនបានច្រើនខ្ពស់ជាងគេ?

ភី ៖ អឺ! ចុះបើបងខ្ញុំនោះរៀនបានត្រឹមថ្នាក់ទី៩ទីអីហ្នឹង ខ្ញុំបានទី៨ ចុះមកហ្នឹងគេមិនមកពី ១២មកមក១! ១១ ១០ ០៩ ០៨។

វិសាល ៖ ចុះបងស្រីដល?

ភី ៖ រៀនបានត្រឹមទី៩បងខ្ញុំហ្នឹង។

វិសាល ៖ បានត្រឹមទី៩?

ភី ៖ ចា!

វិសាល ៖ រៀននៅក្រោមអ្នកមីងមួយថ្នាក់?

ភី ៖ ក្រោមគាត់ឈប់មុនហ្នឹង។

វិសាល ៖ គាត់ឈប់មុន?

ភី ៖ ចា!

វិសាល ៖ បន្ទាប់ពីឈប់ហើយហ្នឹងគាត់ធ្វើអីទៅអ្នកមីង?

ភី ៖ បងខ្ញុំអីនៅធ្វើស្រែធ្វើចម្ការជាមួយម៉ែជាមួយឪខ្ញុំហ្នឹង។

វិសាល ៖ ទាំងអស់គ្នាកូនហ្នឹង?

ភី ៖ ចា! ទាំងអស់គ្នាហ្នឹង។

វិសាល ៖ កាលហ្នឹងនៅចាំទេកាលហ្នឹងមីងមានអាយុប៉ុន្មានហើយ អាចចាំបានទេ?

ភី ៖ អាយុ១៦ហើយកាលហ្នឹងនោះ ១៥-១៦ហើយកាលនឹង ។

វិសាល ៖ ចឹងឈប់រៀន កាលហ្នឹងមីងមានបងប្អូនណាមានគ្រួសារហើយឬនៅ ឬក៏អត់ទាន់មានទាំងអស់គ្នា?

ភី ៖ បើៗបងៗខ្ញុំគេមានគ្រួសារហើយ២នាក់ហើយកាលហ្នឹង ។ បងៗខ្ញុំគេមានគ្រួសារហើយ២នាក់ហើយ បងមួយទៀតគាត់ទៅនៅមោង(មោងឫស្សី) ស្លាប់អត់ដឹង អត់អីដែរ បែកគ្នាអីចឹងទៅ ។

វិសាល ៖ ចាប់ពីពេលឈប់រៀនមកអ្នកមីងមានរឿងមានហេតុការណ៍អីកើតឡើងទេ នៅក្នុងភូមិអីហាដែលបានកើតឡើង អ្នកមីងមានចងចាំអីទេ ដូចជាការទម្លាក់គ្រាប់បែកអីព្រោះថាទាហានខ្មែរក្រហមគេចូលមកចឹង មានទេអ្នកមីង?

ភី ៖ ចា! ចាំបានកាលហ្នឹងគេមានពួករំដោះគេអីចឹងទៅ វាមានពួកធៀវគីអីចឹងទៅ ។

វិសាល ៖ មកដែរ?

ភី ៖ វាមានទាហានគេចឹងទៅ គេដើរធ្វើការៗតាមផ្នែកៗគេហ្នឹង ។

វិសាល ៖ អឺ! កាលហ្នឹងគេចូលមកក្នុងឆ្នាំណាដែរអ្នកមីង?

ភី ៖ ទេ! មិនដឹងឆ្នាំប៉ុន្មានទេអត់ដឹងទេ អត់សូវចាំដែរខ្ញុំ ។

វិសាល ៖ ពេលឈប់រៀនហ្នឹងប៉ុន្មានឆ្នាំដែរ បានឃើញពួកធៀវគីអីចូលមក?

ភី ៖ មករហូតហ្នឹងៗ ។

វិសាល ៖ មករំដោះ?

ភី ៖ ពួកអស់ហ្នឹងមករហូតហ្នឹង មានទាហានមានអីហ្នឹង វានៅមករហូតហ្នឹង ឈប់រៀនហើយព្រោះពួកទាហានហ្នឹងវាមកអីចឹងហើយខ្លាច ពួកខ្ញុំអីហ្នឹងខ្លាចពួកអាធៀវគីអីហ្នឹងកុំអីខ្ញុំម៉េចបានរត់បានទៅស្រុកទៅលើ ។ អាធៀវគីគេខ្លាចទាហានហ្នឹងអី ។

វិសាល ៖ គេច្បាំងគ្នា គេបាញ់គ្នានៅភូមិហ្នឹងហី ឬមួយក៏អត់មានទេ គេគ្រាន់តែដើរទេ?

ភី ៖ បាញ់តិចតួចហ្នឹងវាមិនបាន ប៉ះគ្នាទៅបាញ់គ្នាទៅតិចតួចទៅ វាមិនធ្វើសមរភូមិអីទេ! បើថាមកចឹង ពួករំដោះមកចឹងទៅឃើញពួកទាហានចឹងទៅវាប៉ះគ្នាតិចតួចអីចឹងទៅ វាគ្មានរឿងអីឲ្យខ្លាំងទេហើយមកហើយខ្លាច ទៅកន្លែងណា ចេះតែរត់ទៅរកកន្លែងណាដែលគ្មានទាហានទៅដល់ស្អីចឹងទៅចេះតែទៅៗចឹងទៅ ខ្ញុំរត់ទៅលើទៅ ។ ខ្លាចទាហានទេកុំអីមិតរត់ទៅទេមិនដឹងជាបដិវត្តន៍ស្អីគេទេ ចេះតែទៅៗកាលហ្នឹង ។

វិសាល ៖ អឺ! កាលហ្នឹងឆ្នាំណាដែរមីងអាចចាំបានទេ មីង?

ភី ៖ ៧០ហ្នឹង កាលហ្នឹង៧០ហ្នឹង ។

វិសាល ៖ ចឹងបន្ទាប់ពីឈប់រៀនភ្លាម មីងរត់ទៅលើភ្នាម?

ភី ៖ ចា! នៅបានម៉ាឆ្នាំ នៅកាលហ្នឹងនៅចាំវាមិនបានទេនៅហ្នឹង វាចាំមិនសូវជាបានដែរ នៅមិនដឹងជាឈប់រៀនហើយ ប៉ុនដឹងថារដ្ឋប្រហារភ្លាមឈប់រៀនហើយ រដ្ឋប្រហារភ្លាមឈប់រៀនភ្លាម ។

វិសាល ៖ ហើយភ្លាមៗហ្នឹងដែរហ្នឹងមានបានឃើញទាហានគៀវគីហ្នឹង ពេលរំដោះចូលមក បានខ្លាចទើបឡើងទៅលើ?

ភី ៖ ចា!

វិសាល ៖ ក្នុងឆ្នាំដដែលហ្នឹងហ៎!?

ភី ៖ ឆ្នាំដដែលហ្នឹង ។

វិសាល ៖ អ៎! ហើយកាលទៅលើហ្នឹងមានគេ មានទាហានអីមកអត់ឲ្យទៅ ឬក៏យើងទៅខ្លួនឯង?

ភី ៖ ទៅ ពួកទៅចឹងទៅដូចថាកាលហ្នឹងគេទៅជម្លៀស ទៅហ្នឹងដូចថាមានទាហានចឹងទៅ យើងទៅនៅភូមិណោះ! នោះព្រៃឆ្នូតព្រៃអីចឹងទៅ ឃើញគេទៅហ្នឹងក៏ចេះតែទៅតាម គេតាមឯងអីចឹងទៅ គេថាទៅកន្លែងហ្នឹងសុខ កន្លែងនោះមកអីចឹងទៅចេះតែតាមគេចឹង ទៅដល់ទៅហ្នឹងទៅដល់ដំណាក់ស្ដួលណោះ ។

វិសាល ៖ ទៅដំណាក់ស្ដួល?

ភី ៖ ចា!

វិសាល ៖ ដំណាក់ស្ដួលហ្នឹងឈ្មោះ?

ភី ៖ ដំណាក់ស្ដួលហ្នឹងនៅខេត្តអី នៅខេត្តកំពង់ស្ពឺ អីកំពតណោះ?

វិសាល ៖ ដំណាក់ស្ដួល?

ភី ៖ ចា! ទៅដល់ខ្ញុំទៅនៅហ្នឹង ហើយដល់ពេលនេះ ពេលហ្នឹងគេថាវៃទាហានបែកទាហានអស់ហើយចឹងចុះមកវិញ ។ ចុះមកវិញចឹងប្រជាជនក៏ទៅទាំងអស់ មកក៏ទាំងអស់គ្នាចឹង ទៅម៉ែខ្ញុំអីទៅទាំងអស់ បងប្អូនអីទៅទាំងអស់ចឹងទៅមកវិញ ។

វិសាល ៖ ពេលទៅហ្នឹង ពេលតាមមីងមានប្រសាសន៍ទៅហ្នឹងៗប្រហែលជាភ្លាមៗឆ្នាំ៧០ហ្នឹង មីងណេះ?

ភី ៖ ចា!

វិសាល ៖ កាលទៅហ្នឹង គេទាហានខាងគេរំដោះគេមកហៅឲ្យទៅឬក៏គេប្រកាសឲ្យយើងចេញទៅ ឬក៏យើងចេញទៅដោយខ្លួនឯង?

ភី ៖ គេប្រកាស គេថាបើចង់ដូចថាយើងចង់សុខចឹងទៅ ហើយណាមួយយើងក៏ខ្លាចទាហាន ដែរ ។ ទាហានជំនាន់ហ្នឹងខ្លាចដែរ កូនក្រមុំម្នាក់ៗហ្នឹងក៏ចេះតែគេចដែរជំនាន់ហ្នឹងនោះ ។

វិសាល ៖ បាទ! គេចខាងណាទៅ?

ភី ៖ ហឹស?

វិសាល ៖ គេចខាងណាទៅ?

ភី ៖ គេចទាហានលន់ នល់ហ្នឹង ។

វិសាល ៖ អ៎! ចុះពួកវៀតមិញគេចគេដែរ?

ភី ៖ គេច វៀតមិញហ្នឹងក៏គេចដែរ ពួកហ្នឹងឃើញស្រីៗក្រមុំជំនាន់ហ្នឹងមិនបានទេ ។ ខ្ញុំអីហ្នឹង កាលហ្នឹងស្ទើរក្រមុំស្ទើរចាស់ ពិបាកហ្នងកាលហ្នឹង គេរាងគេវ័យគេក្រមុំរាងពេញទៅ គេធ្វើចាស់ទៅ គេសុីស្លាគេធ្វើអីចឹងទៅ ហើយដល់ខ្ញុំវាធ្វើក្មេងក៏មិនសម ធ្វើចាស់ក៏មិន សម ។ ចង់កុនជាមួយពួកអាវៀតមិញដែរហ្នឹង ។ ខ្ញុំខ្លាចហ្នឹង ខ្ញុំចេះតែទៅនឹងគេនឹងឯងទៅ វៀតមិញរកចាប់ម្តងខ្ញុំហក់ទឹក ។

វិសាល ៖ ពេលចេញទៅហ្នឹង ទៅចេញទៅទាំងអស់ម៉ាភូមិឬក៏ទៅតែខ្លះនៅសល់ខ្លះ?

ភី ៖ ទៅខ្លះនៅខ្លះចឹងទៅ ដល់ហើយក្រោយមកទៅទាំងអស់អាលឹង ។ វាកៀរទៅទាំងអស់ អាលឹងទៅ គ្មានអាណានៅមួយទេ ។

គន្ធី ៖ វៀតមិញហ្នឹងមកធ្វើអីដែរមីង?

ភី ៖ ដឹងគេទេ ការងាររបស់គេខ្ញុំមិនសូវជាដឹងដែរកាលហ្នឹង ឃើញតែតុគេ យួនហ្នឹង ហើយដល់ហើយហ្នឹងមានពួកយៀកកុងទៀត កាលជំនាន់ហ្នឹងហា មានទាំងពួកវៀតមិញ ហើយនឹងពួកយៀកកុងហ្នឹង ។ អាពួកយៀកកុងហ្នឹងនៅតាមផ្ទះយើងហ្នឹងគ្រប់គ្នាប្រជាជន ហ្នឹង ។ ហើយពួកអាវៀតមិញហ្នឹង គេជិះកន្ធុំរុយមកគេចុះមកហ្នឹងហ្នង ។ វៀតមិញហើយ នឹងយៀកកុងហ្នឹងគេមិនត្រូវគ្នាទេ គេមិនសូវត្រូវគ្នាទេ ហើយយើងហ្នឹងចេះ តែខ្លាច អាពួកអស់ហ្នឹងទាស់គ្នាទៅ ចេះមិត(រត់) នាំគ្នាជម្លៀសទៅចឹងទៅ ។

វិសាល ៖ ទៅដល់ឈ្មោះអីមិញមីង កន្លែងមីងមានប្រសាសន៍ហា?

ភី ៖ ខ្ញុំទៅអាខ្លះទៅមិនដល់ទេ ទៅអាខ្លះដំណាក់ស្នួលហ្នឹង ។

វិសាល ៖ ដំណាក់ស្នួល?

ភី : ចា!

វិសាល : ចឹងបន្ទាប់ពីជម្លៀសទៅហ្នឹង មីងនៅដំណាក់ស្ពួលរហូតមក?

ភី : នៅដំណាក់ស្ពួលរហូតចឹងទៅ ចុះមកវិញហ្នឹង ។

វិសាល : ចុះមកវិញហ្នឹងឆ្នាំណាចុះមកវិញដែរ?

ភី : ខ្ញុំមិនចាំបានទេកាលហ្នឹង មិនដឹងជាទៅប៉ុន្មានឆ្នាំភ្លេចដែរ កាលហ្នឹងជំនាន់ហ្នឹង ។

វិសាល : ពេលមកវិញហ្នឹង កាលហ្នឹងមានដែលឃើញគេជម្លៀសប្រជាជនពី កាលហ្នឹងបែកភ្នំពេញនៅកាលហ្នឹង?

ភី : នៅទេ ទេមកហ្នឹងប្រជាជនក៏ទៅដែរកាលហ្នឹង ប្រជាជនហ្នឹងក៏ទៅក៏មកដូចគ្នាចឹងខ្ញុំពិបាកចាំដែរកាលហ្នឹងយូរពេក ។ ហើយមិនសូវជាយកចិត្តទុកដាក់ពីរឿងហ្នឹងប្រវត្តិសាស្ត្រហ្នឹងផង ។

វិសាល : បាទ! ខ្ញុំយល់អ្នកមីង ខ្ញុំយល់ថាអ្នកមីងអត់ដឹងចាំអស់ ចេះព្យាយាមធ្វើយ៉ាងម៉េចមីងអាចគិតចេញជាឆ្នាំអីបាន ។

ភី : អឺម ។

វិសាល : បាទ! កាលហ្នឹងពេលទៅនៅតំបន់ថ្មីអីហ្នឹង នៅហ្នឹងទៅធ្វើអីទៅរស់នៅក្នុងតំបន់ថ្មីហ្នឹង?

ភី : ពួកខ្ញុំៗដូចនារីចឹងគេនៅគេឲ្យចូលតាមអង្គភាពគេនារី តាមមន្ទីគេហៅថាមន្ទីគេហ្នឹង ។ នៅមន្ទីទៅ គេអប់រំយើងចឹងទៅ គេនៅមន្ទីគេហ្នឹង ហើយម៉ែឪខ្ញុំនៅតាមភូមិអ្នកស្រុកនឹងគេនឹងឯងចឹង ខ្ញុំមួយគេយកទៅចូលក្នុងមន្ទីគេនៅក្នុងអង្គភាពគេទៅ ។

វិសាល : អ៎! ចឹងៗតំបន់ហ្នឹង អាចថាជាតំបន់រំដោះ?

ភី : ចា!

វិសាល : ក្រោមការគ្រប់គ្រងរបស់អ្នករំដោះខ្មែរក្រហម?

ភី : ចា! រំដោះគេហើយកាលហ្នឹង ។

វិសាល : បាទ! ក្នុងភូមិគេ ឬក៏នៅជិតភ្នំ ឬក៏នៅជិតព្រៃឬក៏នៅម៉េចដែរ?

ភី : នៅៗ ហ្នឹងរបៀបភូមិដែរហា កាលខ្ញុំទៅហ្នឹងនៅក្បែរភូមិដែរដូចថាភូមិទៅអាផ្លូវចូលចឹងខ្ញុំ ពួកខ្ញុំអាមន្ទីពួកខ្ញុំនៅហ្នឹងប្រហែលហ្នឹងចឹងទៅណា ។ ហើយផ្ទះប្រជាជននៅនេះចឹងទៅគ្រាន់ថាវានៅព្រៃដែរមានព្រៃភ្នំព្នេងព្រៃអីចឹងហានៅ ហ្នឹង ខ្ញុំនៅតូចដែរកាលហ្នឹង ។

វិសាល : បាទ! ហើយមុនពេលដែលគេជម្លៀសទៅតំបន់ហ្នឹង អ្នកមីងមានធ្វើការអីទេឬក៏គ្រាន់តែជួយឪពុកម្តាយធ្វើស្រែទេ?

ភី ៖ អត់មានធ្វើអីទេខ្ញុំ ។

វិសាល ៖ អ៎! បាទ ហើយដល់ពេលទៅដល់នោះមិញមីងមានប្រសាសន៍ថា គេចាត់ឲ្យមីងទៅធ្វើការនៅមន្ទីអីគេ?

ភី ៖ នៅក្នុងមន្ទីគេ នៅក្នុងអគ្គភាពគេហ្នឹង ។

វិសាល ៖ អគ្គភាព?

ភី ៖ អគ្គភាពគេៗអប់រំយើងខ្លះៗចឹងទៅ ។

វិសាល ៖ អគ្គភាពហ្នឹងអគ្គភាពអីដែរទៅអ្នកមីង?

ភី ៖ ទេ! មិនដឹងគេហៅស្អីទេច្រើនមន្ទី១០៩ៗគេហ្នឹង មន្ទីខ្ញុំមិនដឹងដែរ ។

វិសាល ៖ មន្ទី១០៩?

ភី ៖ អឺម! វាថាមន្ទី១០៩ៗហ្នឹង ។

វិសាល ៖ មន្ទីហ្នឹងមន្ទីអីដែរ ដូចថាមន្ទីដាក់ៗស្អីសម្រាប់យោធា ឬក៏សម្រាប់ពេទ្យឬមួយក៏យ៉ាងម៉េចដែរ?

ភី ៖ ដូចថាអត់មានស្អីទេ វាទូទៅមិនដឹងជាអ្នកណាជាអ្នកណីអីទេ ។

វិសាល ៖ អ៎! មានស្គាល់មេកើយគេនៅហ្នឹងអីទេអ្នកមីង?

ភី ៖ ថីមិនស្គាល់កាលហ្នឹង ។

វិសាល ៖ មេហ្នឹង?

ភី ៖ កាលហ្នឹងតាគុំហ្នឹងគាត់នៅគ្រប់គ្រងមន្ទីហ្នឹង ។

វិសាល ៖ តាគុំ?

ភី ៖ អឺម!

វិសាល ៖ តាគុំហ្នឹងអ្នកខាង អ្នកពីហ្នឹងទៅឬក៏អ្នកនៅខាងណោះ?

ភី ៖ អ្នកស្រុកណាទេ គាត់ហ្នឹង ។ គាត់ហ្នឹងនៅស្រុកត្រាំកក់អីទេតាគុំហ្នឹងគាត់មកនៅធ្វើខ្មែរក្រហមនៅស្រុកយើងហ្នឹង គាត់មកនៅវិទ្យាហានលន់ នល់ ។

វិសាល ៖ អ៎! គាត់មកនៅវិទ្យាហានលន់ នល់ហីមីង?

ភី ៖ ហ្នឹងហើយ ។

វិសាល ៖ បាទ! ពេលទៅដល់ហ្នឹងចឹងគេបែងចែកឲ្យគ្រួសារអ្នកមីងទៅលោកតាលោកយាយអីទៅនៅម៉ាដុំ ហើយអ្នកមីងគេឲ្យយកទៅដាក់នៅមន្ទី១០៩?

ភី ៖ អឺ!

វិសាល ៖ ហើយចុះអ្នកណាគេអ្នកយកអ្នកមីងទៅដាក់ចូលទៅក្នុងមន្ទីហ្នឹង?

ភី ៖ អាហ្នឹងពួកអ្នកគេ អ្នកស្រុក អ្នកភូមិហ្នឹងគេនៅដូចថា អូនឯងចឹង មានចឹងម៉ែឪចឹងទៅ អូនឯងទៅនៅចឹងផ្សេងចឹងទៅ យើងទៅនៅផ្សេងតាមខ្សែរយៈគ្នា យើងចេះតែនាំគ្នាទៅ ចឹងទៅគ្មាន...ឃើញគេនៅទៅនៅគេចឹងទៅ មានអីយប់ឡើងគេឲ្យរាំឲ្យច្រៀងអា សិល្បៈហ្នឹងមានដឹងអីៗ រាំច្រៀងលេងទៅជាមួយគេជាមួយឯងទៅ យើងទៅដឹងអី នៅក្មេងដែរមានទៅនៅធំអី កាលហ្នឹង។

វិសាល ៖ បាទ! ចឹងនៅក្នុងកងហ្នឹង មានប្រុសមានស្រីឬមានសុទ្ធតែស្រីៗ?

ភី ៖ មានប្រុសសុទ្ធតែចាស់ៗ ។

វិសាល ៖ ចាស់ៗ ។

ភី ៖ ដូចថាអាយុគេរាងច្រើនៗដូចជាឪដូចអីចឹងទៅណា ចឹងទៅប៉ុនវាមានចាស់ៗច្រើនចឹងទៅ វាមានដូចស្រីដូចអីដែរហាណា ក្នុងហ្នឹងក៏វាមិនមានច្រើនប៉ុន្មានដែរកាលហ្នឹងវាមិនដល់ទៅ ប្រហែលជា២០នាក់អីទេ នៅក្នុងអង្គភាពហ្នឹង មិនច្រើនប៉ុន្មានទេ។

វិសាល ៖ ចុះកាលហ្នឹង បងៗរបស់មីង មីងដល?

ភី ៖ មិនដឹងគេទៅឯណាទេ ខ្ញុំអត់ដឹងដែរ ។

វិសាល ៖ អូ! ចឹងកាលហ្នឹងអត់មានទៅជាមួយគ្នាទេ?

ភី ៖ អត់ទេគេចេញទៅណាៗខ្ញុំមិនដឹងទេ ។

វិសាល ៖ អ៎!

ភី ៖ មិនដឹងគេទៅផង គេទៅហ្នឹងមិនមែនទៅជាមួយគ្នាទេ។ ខ្ញុំទៅនៅជាមួយម៉ែខ្ញុំ ឪខ្ញុំហើយនឹងប្អូនខ្ញុំទេ។

វិសាល ៖ គាត់មីងមានប្រសាសន៍ហ្នឹងនៅរស់ទេសព្វថ្ងៃហ្នឹង មីងមានបានដឹងដំណឹងអីទេ?

ភី ៖ មិនដឹង ។

វិសាល ៖ អត់ដឹងទេ ។

ភី ៖ បែកគ្នាទៅ...ឲ្យតែអ្នកធ្វើការជាមួយគ្នាប៉ុន្មានខ្ញុំមិនដែលបានដឹងស្អីតិចតួចពីគ្នាទេ ។

វិសាល ៖ បាទ! មីងនៅមន្ទី១០៩នៅឈ្មោះតំបន់ហាមីង ខ្ញុំសុំទោស ខ្ញុំភ្លេចហើយមីងឈ្មោះតំបន់អីដែរ?

ភី ៖ តំបន់ហ្នឹងអី តំបន់មិនដឹងជា... ។

វិសាល ៖ មីងមិញថាអីគេមិញហ្នឹងមីង?

ភី ៖ ដំណាក់ស្នួល ។

វិសាល ៖ ដំណាក់ស្នួល បាទដំណាក់ស្នួល ។ នៅដំណាក់ស្នួលមន្ទី១០៩ហ្នឹង គេឲ្យមីងធ្វើអីគេដែរនៅហ្នឹងមីង?

ភី ៖ ទៅមានឲ្យធ្វើអីទេ ពួកខ្ញុំវានៅតូចៗចឹងដូចថាមានពួកពូៗហើយគេនៅនារីធំៗចឹងគេទៅកាប់ចម្ការ កាប់អីចឹងហា គេឲ្យខ្ញុំឡើងដើមឈើជាច្រៀងឲ្យគេស្ដាប់ ។

វិសាល ៖ អត់ធ្វើអីទេ ឡើងដើមឈើច្រៀងឲ្យគេស្ដាប់?

ភី ៖ ឡើងច្រៀនឲ្យគេស្ដាប់ ដល់ៗម៉ោងមកវិញហ្នឹងមកហ្នឹងគេទៅចុះខ្ញុំវានៅតូចជាងគេនោះ ។

គន្ធី ៖ ហាត់សិល្បៈហ្នឹងមីងហី?

ភី ៖ អើ ហាត់សិល្បៈគេរាំ គេលេងគេអីធម្មតាចឹងហា ដល់ពេលទៅធ្វើការចឹងខ្ញុំធ្វើអីមិនកើតនឹងគេទេ គេឲ្យឡើងអាចុងកណ្ដាលមួយអាកន្លែងចម្ការគេហ្នឹង ឡើងច្រៀងទៅ ចេះតែច្រៀងទៅ ច្រៀងឲ្យគេស្ដាប់ហ្នឹង ហើយដល់ៗម៉ោងចុះមក ។ មកហូបបាយ មកនឹងគេដែរទៅ ។

គន្ធី ៖ ច្រៀងបទអីដែរមីង?

ភី ៖ បទអាពូកងឈូបអឺយអីទៅ អានិរសារអង់អាចទៅហើយមិនដឹងជាស្អីទៅភ្លេចអស់ហើយយូរហើយ ។

គន្ធី ៖ មីងច្រៀងគ្នាប៉ុន្មាននាក់ដែរ?

ភី ៖ ដល់ឡើងច្រៀងឡើងអាពេលធ្វើការហ្នឹងឡើងម្នាក់ឯង ដល់ពេលយប់ឡើងច្រៀងអាទាំងអស់គ្នាហ្នឹងទាំងប្រុសទាំងស្រីហ្នឹង ។

គន្ធី ៖ ប៉ុន្មាននាក់ដែរទៅ?

ភី ៖ ជិត២០នាក់ដែរហ្នឹង ។

គន្ធី ៖ គេហាត់ច្រៀងហីមីង?

ភី ៖ ចា! គេហាត់ច្រៀង ។

គន្ធី ៖ មីងចាំម៉ាបទទេមីង?

ភី ៖ អត់ចាំសោះ ។

គន្ធី ៖ ចាំអីដូចបទអីបទនិរសារអីគេមិញ?

ភី ៖ អឺម...អត់មានចាំអីសោះ អត់មានចាំទេលែងចាំហើយចប់ លែងចាំលែងអីទាំងអស់ហើយឥលូវហ្នឹង ឥលូវអត់មាននេះណា ។

វិសាល ៖ បាទ ពេលមុននេះបន្តិច មីងមានប្រសាសន៍ថាយប់ឡើងគេឲ្យរាំគេឲ្យច្រៀងអាហ្នឹងគេបង្ហាត់ឬក៏គេឲ្យយើងធ្វើ?

ភី ៖ គេបង្ហាត់ៗ ឲ្យតាមសិល្បៈគេណា គេបង្ហាត់ឲ្យតាមសិល្បៈគេ ។

វិសាល ៖ អ៎! ការបង្ហាត់ហ្នឹងមានមេក្រុមគេ មានមេកើយអីដែរទេ?

ភី ៖ អត់ទេ ឧទាហរណ៍ដូចថា អាគេមកនៅកន្លែងហ្នឹងមុនអីចឹងទៅ គេចេះអាបទហ្នឹងមុនចឹងទៅគេប្រាប់យើងឲ្យច្រៀងទៅ គ្មានមេគ្មានកើយអីគួរឲ្យអស្ចារ្យទេ ។ គ្រាន់តែថាធ្វើតាមតែគ្នាហ្នឹងទៅហ្នឹង ។

វិសាល ៖ ដល់ពេលចេះចាំអីចឹងទៅគេមានឲ្យទៅសម្តែងឃោសនាអីទេ?

ភី ៖ អត់ទេ មានស្អីទេ ។

វិសាល ៖ អត់ទេ ។

ភី ៖ អត់ទេពួកខ្ញុំហ្នឹង អាពួកសិល្បៈគេត្រឹមត្រូវហ្នឹងបានគេទៅដេរ្យងហ្នឹង អាពួកខ្ញុំហ្នឹងបានតែច្រៀងលេងហ្នឹង ។

វិសាល ៖ មានស្គាល់គេនៅក្នុងមន្ទីរ១០៩ហ្នឹងទេ ថាអ្នកធ្លាប់ស្គាល់ អ្នកសាច់ឈាម សាច់ញាតិអីបងប្អូនអី ឬក៏អ្នកស្គាល់គ្នាអីមានទេ?

ភី ៖ អ្នកស្គាល់គ្នាហ្នឹងភ្លេចគ្នាអស់ហើយខ្ញុំក៏ភ្លេច សូម្បីតែឈ្មោះភ្លេចអស់ហើយ និយាយទៅអត់មានលាក់ទេភ្លេចអស់ហើយហ្មង ។ ភ្លេចហ្មង អត់មានលាក់ទេចាំបានតែ កាលហ្នឹងមិនដឹងជាអ្នកណាខ្លះឈ្មោះ គាត់ហ្នឹង ដឹងថាគាត់ហ្នឹងមេចឹង ក៏ចាំគាត់ទៅហើយក្រៅពីហ្នឹងទៅមិនដឹងជាទៅណាអីណាអស់ទេ ទៅខ្ញុំមិនដឹងដែរ ។

វិសាល ៖ នៅមន្ទីរ១០៩ហ្នឹងចឹងមីងអត់មានធ្វើអីទេ?

ភី ៖ អត់មានធ្វើអីទេ ចេះតែទៅដូនណាទៅចឹងទៅជួយដាំពោត ជួយដាំគេស្អីតិចតួចហ្នឹង បន្លែបន្ការស្អីតិចតួចហ្នឹង គិតមើលទៅគិតកាលហ្នឹងខ្ញុំដូចថាក្មេងចឹង ។ ក្នុងចំណោមគ្រួសារចឹងដូចថាយើងតូចជាគេចឹង យើងធ្វើអីធ្វើទៅមិនធ្វើអីធ្វើទៅស្រេច តែចិត្តយើងទៅ ។

វិសាល ៖ ចុះហូបចុកអីគ្រប់គ្រាន់ទេអី កាលហ្នឹង?

ភី ៖ រឿងហូបចុក មានតែរឿងអាស្លឹករងៀងអាក្រហមៗហ្នឹងហើយអំបិលម្រេចទេ អត់មានអីហូបទេ ។

វិសាល ៖ ចុះអង្ករអីអត់ទេ?

ភី ៖ អង្ករអីអត់ទេ ជួនណាបបរហូបហ្នឹងមានស្អី ។

វិសាល ៖ កាលហ្នឹងបាយរួមមាននៅ ឬក៏នៅទេ?

ភី ៖ បាយ កាលហ្នឹងមិនទាន់រួមទេ រួមតែតាមអង្គភាពទេកាលហ្នឹង ។ ប៉ុនវាគ្មានដែរកាលហ្នឹង កន្លែងនេះសុទ្ធតែពួកនេះហ្នឹង ពួកផ្សេងហើយកន្លែងនោះពួក ផ្សេងមានស្រូវមានអង្ករ អីចឹង ។

វិសាល ៖ អ៎! មាន...?

ភី ៖ ហើយពួកខ្ញុំហូបអង្ករហ្នឹងមិនមានបាយមានចានទេ ដាក់ត្រឡោកទៀត ។

វិសាល ៖ ដាក់ត្រឡោក?

ភី ៖ ហូបបាយកាលជំនាន់ហ្នឹង ។ មានទេ តែបរបរ ពូៗហ្នឹងគាត់ដើរដាក់ដុងទន្សាយដុងអី បានចឹង យកស្លដាមួយស្លឹក រងៀងអីចឹងទៅ ប៉ុនខ្ញុំមិនហូបមិនអីទេសុខចិត្តអាអំបិលបុក អង្ករហ្នឹងចឹងទៅ ។

វិសាល ៖ នៅទីនោះប្រហែលជាប៉ុន្មានឆ្នាំដែរមីងកាលជំនាន់ហ្នឹង មីងចាំបានទេ?

ភី ៖ នៅប្រហែលជាម៉ាឆ្នាំ ឬក៏នៅប្រហែលជាមិនដល់ម៉ាឆ្នាំទេ ខ្ញុំភ្លេចដែរហើយ ។

វិសាល ៖ នៅប្រហែលជា នៅយូរគ្រាន់បើទេ បានធ្វើ?

ភី ៖ នៅយូរគ្រាន់បើដែរហ្នឹង នៅកន្លែងហ្នឹងយូរដែរ ។

វិសាល ៖ រួចទៅបានគេឲ្យមកវិញ?

ភី ៖ បានគេឲ្យមកកវិញ សុំគេមក ។

វិសាល ៖ សុំគេមក?

ភី ៖ ឃើញគេមក គេមកធ្វើព្រីបៗខ្ញុំដូចថាគេមិនដឹងជាឲ្យខ្ញុំទៅធ្វើអីដែរទេ ណាមួយកាលហ្នឹង នៅជំនាន់ដំបៅយួនហា ។

វិសាល ៖ បាទ!

ភី ៖ អាកាលហ្នឹងខ្ញុំកើតអាដំបៅយួនហា ។ កើតអាដំបៅហ្នឹងពេញជើង គេថាទៅធ្វើអីទេដើរ មិនរួចហ្នឹង សុខចិត្តនឹកស្រុកមកទាំងឈឺ ជើងហ្នឹង ។

វិសាល ៖ បាទៗ ៗ! នៅទីនោះនៅយូរដែរចឹង មានដែលគេធ្វើប្រវត្តិរូបអីទេ?

ភី ៖ អត់ទេ ។

វិសាល ៖ អត់មានគេសួរថាប្រវត្តិគ្រួសារម៉េចៗនៅទេ?

ភី ៖ អត់ទេ ។

វិសាល ៖ ក្រោយមកបានសុំគេមកវិញមក មកទាំងគ្រួសារហ្នឹងឬមកតែឯងទេ?

ភី ៖ មក១ហ្នឹងជាមួយតាមអង្គភាពគេ ។ មកជាមួយតាមអង្គភាពគេហ្នឹងមក ម៉ែឪខ្ញុំហ្នឹងផ្សេងទៅ គាត់មកនៅផ្ទះទៅ ហើយខ្ញុំវិញ ហ្នឹងក៏ខ្ញុំនៅតាមអង្គភាពហ្នឹងដែរ ខ្ញុំអត់មាននៅផ្ទះជាមួយម៉ែឪដូចគេទេ ។

វិសាល ៖ អូ! ចឹងមកវិញ?

ភី ៖ ប៉ុន បើថាទៅចឹងទៅហ្នឹងវាវាងយូរ១ហ្នឹងជិត២ឆ្នាំហើយ ទៅ ។

វិសាល ៖ ជិត២ឆ្នាំ?

ភី ៖ ហ្នឹងហើយទៅដល់ មកដល់នៅនេះមកបានមិនដឹងជាប៉ុន្មានឆ្នាំទេ ខ្ញុំចាំអារាងវគ្គអារឿងបែកភ្នំពេញបែកអីហ្នឹង ខ្ញុំវាងវគ្គអាហ្នឹង ។

វិសាល ៖ បាទ! បែកភ្នំពេញឆ្នាំ៧៥ ១៧មេសា ៧៥ ។

ភី ៖ មកមុនហើយ មកមុន ។

វិសាល ៖ មក១ នៅហ្នឹងប្រហែលជាបាន២ឆ្នាំក៏សុំគេមកវិញ ហើយមកវិញហ្នឹង?

ភី ៖ មកតាមអង្គភាពគេ ។

វិសាល ៖ អង្គភាព?

ភី ៖ អង្គភាពគេហ្នឹងក៏ត្រូវមកវិញចឹងទៅ ក៏សុំគេមកវិញជាមួយគេចឹងទៅ ។

វិសាល ៖ មីងមានចាំឈ្មោះអង្គភាពមីងទេ ឬក៏អត់ស្គាល់?

ភី ៖ អង្គភាពស្រុក១០៩ហ្នឹង ។

វិសាល ៖ អង្គភាពស្រុក១០៩?

ភី ៖ មិនសូវស្គាល់មិនសូវអីទេ ប៉ុនគេថាកាលជិនាន់ហ្នឹងគេហៅស្រុកគិរីវង់ហ្នឹងស្រុក១០៩ ។

វិសាល ៖ បាទ!

ភី ៖ ខេត្តតាកែវហ្នឹងគេហៅតំបន់១៣ ។

វិសាល ៖ តំបន់១៣ ។

ភី ៖ អឹម!

វិសាល ៖ ចឹងតំបន់១៣ ចឹងមានដឹងថាពីណាគេអ្នកគ្រប់គ្រងតំបន់១៣ហ្នឹងទេមីង?

ភី ៖ ដឹង ឈ្មោះតាសោម ។

វិសាល ៖ តាសោម?

ភី : ចា!

វិសាល : គាត់ស្លាប់ឬរស់ដែរ?

ភី : គាហ្នឹងបែបស្លាប់ហើយ គាត់....។

វិសាល : អ៊ំ!

ភី : គាត់យូរហើយ។

វិសាល : បាទ! ស្រុកគិរីវង់ហ្នឹងគេស្រុកអីគេកាលហ្នឹង?

ភី : ស្រុកគិរីវង់ហ្នឹង។

វិសាល : ឬក៏ឈ្មោះចឹងដដែល?

ភី : ស្រុក១០៩ហ្នឹងហើយ។

វិសាល : ស្រុក១០៩?

ភី : ចា កាលពីសង្គមគេហៅស្រុកគិរីវង់ តែដល់ពេលពួកវាគ្រប់គ្រងហ្នឹងគេហៅស្រុក ១០៩។

វិសាល : បាទៗ! ចឹងមានស្គាល់គេមេកើយគេអីទេមីង?

ភី : ជីមិនស្គាល់។

វិសាល : ឈ្មោះអីទៅ?

ភី : ឈ្មោះតាគុំហ្នឹងទៅ តាទិត្យហ្នឹងទៅ យាយបូហ្នឹងទៅ យឿនហ្នឹងទៅ។

វិសាល : ពួកគាត់ហ្នឹងសុទ្ធតែអ្នកនៅរស់ទេ ឬក៏ពួកគាត់ស្លាប់អស់ហើយ?

ភី : មិនដឹង អត់ដឹងបែកមិនស្គាល់អត់ដឹង មិនដែលឮដំណឹងពីគ្នាផង។

វិសាល : អ៊ំ!

ភី : មិនដែលស្គាល់គ្នា។

វិសាល : បាទៗ!

ភី : សូម្បីតែអ្នកធ្វើការ អាអ្នកស្និទ្ធស្នាលគ្នា ស្រលាញ់គ្នាម៉េចក៏មិនដែលជួបគ្នាដែរ។

វិសាល : បាទៗ! នៅៗតំបន់ហ្នឹង ពេលដែលអ្នកមីងត្រលប់មកវិញប្រហែលជាឆ្នាំ៧៣-៧៤ហ្នឹង ត្រលប់មកពីអី...ដំណាក់ស្លួលវិញហា ភូមិហ្នឹងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ទាហានរំដោះហើយ ទាហានខ្មែរក្រហមហើយឬក៏នៅទេ?

ភី : នៅ ខ្មែរក្រហមអូសទាញណោះ។

វិសាល : អូ! ប្រទាញប្រទោងគ្នា?

ភី ៖ ហ្នឹងហើយ នៅប្រទារប្រទោងគ្នាហ្នឹងទៀតកាលហ្នឹង ការពិតវាមិនទាន់ពេញធីងទេ ។

វិសាល ៖ អ៎! បាទ!

ភី ៖ ហើយពួកអាកន្ទ្វេងសហ្នឹងក្រែងអាជំនាន់កាលខ្ញុំទៅហ្នឹង ខ្ញុំខ្លាចពួកអាកន្ទ្វេងសហ្នឹងណាស់ទៅ ខ្លាចអាកន្ទ្វេងសហ្នឹងណាស់ ។

វិសាល ៖ បាទ! ចឹងមកវិញៗហ្នឹង គឺមកវិញប្រហែលជានៅហ្នឹងប្រហែលជាបានប៉ុន្មានឆ្នាំដែរបានបែកភ្នំពេញមីង ប្រហែលជានៅយូរគួរសមទេអាចចាំបាន?

ភី ៖ នៅយូរគួរសមដែរ នៅយូរដែរ ។

វិសាល ៖ ប្រហែលជាមួយឆ្នាំទេមើលទៅ?

ភី ៖ អើ! ប្រហែលជាម៉ាឆ្នាំហ្នឹង ។

វិសាល ៖ បាទៗ! មួយឆ្នាំ ។

ភី ៖ ព្រោះថាឥលូវបើគិតពីរឿងទៅពី៧១-៧២ហ្នឹងហើយ...។

វិសាល ៖ ហើយ៧៣មកវិញ ៧៣-៧៤បងថាមកវិញ?

ភី ៖ ចា!

វិសាល ៖ បាទ! នៅប្រហែលជាប៉ុន្មានឆ្នាំបែកភ្នំពេញ?

ភី ៖ នៅអាហ្នឹងនិយាយទៅប្រហែលជាមិនច្បាស់ទេ អារឿងឆ្នាំហ្នឹង ។ វាមិនទាន់ទេ ។

វិសាល ៖ វា៣០ឆ្នាំហើយអ្នកមីង ។

ភី ៖ ចា! វាអត់មានទាន់ថាច្បាស់ទេ ។

វិសាល ៖ យូរហើយ?

ភី ៖ ដូចថាឆ្នាំប៉ុន្មានអីប៉ុន្មានហ្នឹងវាមិនច្បាស់ទេ ។

វិសាល ៖ ពេលត្រលប់មកនៅភូមិហ្នឹងវិញ គឺមិនមែនថាទៅនៅផ្ទះខ្លួនឯងទេគឺនៅក្នុងកងអង្គភាព?

ភី ៖ ចា!

វិសាល ៖ អង្គភាពស្រុក១០៩?

ភី ៖ ហ្នឹងហើយ ។

វិសាល ៖ ពេលហ្នឹងក្នុងអង្គភាពហ្នឹងមានតួនាទីដូចថាធ្វើ គេឲ្យធ្វើអីទៅ?

ភី ៖ នៅអង្គភាពហ្នឹងទៅ នៅគេឲ្យទៅជញ្ជូនអង្ករ ជញ្ជូនអីចឹងទៅ ទៅកើបស្រូវកើបអីទៅប្រមូលដូចថាកន្លែងឯណាគេវៃបានចឹងទៅ រំដោះបានចឹងយើងក៏យកស្រូវយកអីមកទុកឲ្យកងទ័ពគេស៊ីចឹងទៅ ។

វិសាល ៖ អ៎! កន់ទ័ព?

ភី ៖ កាលហ្នឹង ។

វិសាល ៖ កន់ទ័ពរំដោះ កន់ទ័ពខ្មែរក្រហមហ្នឹងហីមីង?

ភី ៖ ចា! ហ្នឹងទៅយកទៅមកហ្នឹងចឹងទៅដូចថាបែកត្រលប់ចឹង ទៅត្រលប់ទៅដូចថាបែកគីរីចឹង ទៅគីរីហ្នឹងទៅយកអាគេហៅជ័យភ័ណ្ឌៗ ហ្នឹងហា ទៅយកមកតាមអន្តភាពហ្នឹងទៅដង្ហែរគ្នា ចឹងទៅទទូរកន្លែងម៉ាស្រូវទៅ ។

វិសាល ៖ ចឹង ម៉ាអន្តភាពមីងនៅ១០៩ហើយភារកិច្ចមីងគឺទៅយកអង្ករ ទៅយកអីទៅយករបស់ ជ័យភ័ណ្ឌ?

ភី ៖ ហ្នឹងហើយ ។

វិសាល ៖ ហ្នឹងចឹងគេមិនហៅថា ក្នុងកងសេដ្ឋកិច្ចមែនទេមីង?

ភី ៖ មិនមែនទេដូចថាអ្នកណាក៏ទៅយកខចឹងដែរ ។ ឲ្យតែនេះចឹងគេឲ្យទៅយកហើយ ។

វិសាល ៖ ចុះមេការហ្នឹង គេឲ្យមីងស្គាល់គេទេមេកងរបស់មីងហា?

ភី ៖ មេកងដូចខ្ញុំប្រាប់មិញហ្នឹង ។

វិសាល ៖ ដដែលហ្នឹង?

ភី ៖ អឺម! ទាំងអស់ហ្នឹងស្រុកហ្នឹង មានប៉ុណ្ណឹង ។

វិសាល ៖ អត់...បាទ! ហើយធ្វើចឹងរហូតដល់តែបែក?

ភី ៖ ចា!

វិសាល ៖ ឬក៏...?

ភី ៖ ចាទាល់ដល់បែក ។

វិសាល ៖ ឬក៏ពេលទាហានគេវិតចូលទៅភ្នំពេញក៏ចេះតែទៅតាមទាហានគេទៅ?

ភី ៖ អត់ទេ នៅហ្នឹងខ្ញុំនៅហ្នឹងរហូតហ្នឹងអត់មានទៅណាទេ

វិសាល ៖ នៅរហូតចឹងទៅអត់មានទៅណាទេ

ភី ៖ នៅតែហ្នឹងរហូត មិនដែលទៅដឹងការរាក់ជ្រៅអីមិនសូវជាដឹងអីនឹងគេទេ ។

វិសាល ៖ កិច្ចការរបស់មីងគឺចឹងរហូត?

ភី ៖ ចា!

វិសាល ៖ ហើយចុះបងប្អូនវិញពេលម៉ាឆ្នាំដែលមីងនៅក្នុងភូមិមុនបែកភ្នំពេញហា បងប្អូនមីងនៅក្នុង ភូមិហ្នឹងដែរទេ ឬក៏រស់នៅខាងក្រៅ?

ភី ៖ ទៅនៅក្នុងភូមិស្រុកកំណើតគេហ្នឹងហើយកាលនេះ គាត់នៅលើហ្នឹងដែរ ។

វិសាល ៖ ដែលខស្សាហ៍បានជួបគ្នាទេ?

ភី ៖ ជួបគ្នា ដល់ហើយបែកហើយមកនៅតាមភូមិទៅ ដល់ពេលចិនហើយទៅនៅតាមអន្តភាព គេដូចថាគេប្រមូលចិន ជម្លៀសៗដូចបងខ្ញុំអីគេជម្លៀសទៅខាងកោះអណ្តែត កោះអីចិនទៅហើយនៅតែខ្ញុំនៅហ្នឹងទៅ គេជម្លៀសបងប្អូនៗហ្នឹងមានបានឲ្យជួបជុំគ្នាទេ ។

វិសាល ៖ ចិនពី៧/៨របូតដល់ដាច់ភ្នំពេញអ្នកមីងធ្វើចិនរបូត ដើរប្រមូលរបស់អន្តរអីចិនទៅ?

ភី ៖ អឺម! ដើរប្រមូលរបស់អន្តរអីហ្នឹងទៅច្រកហ្នឹង ត្បាញអ៊ីអីធម្មតាចិន ។

វិសាល ៖ អ៎!

ភី ៖ ដាំដំណាំអីធម្មតាអីទៅ ។

វិសាល ៖ អ៎! បាទ! ហើយឥលូវដល់ពេលបែកភ្នំពេញហើយ នៅណាវិញទៅបែកភ្នំពេញហើយ?

ភី ៖ នៅហ្នឹងដែរ ។

វិសាល ៖ នៅហ្នឹងដែរ?

ភី ៖ ចា!

វិសាល ៖ អត់ទៅណាទេ?

ភី ៖ នៅតែហ្នឹង នៅហ្នឹងទាល់ឥលូវហ្នឹង ។

វិសាល ៖ ពេលបន្ទាប់ពីបែកភ្នំពេញហើយ អ្នកមីងធ្វើអីវិញទៅអ្នកមីង?

ភី ៖ ដល់បែកភ្នំពេញ ខ្ញុំនៅអាយុបាន១៨ឆ្នាំ ។

វិសាល ៖ អាយុ១៨ឆ្នាំ ។

ភី ៖ ខ្ញុំចាំបានអាយុខ្ញុំ១៨ឆ្នាំ អាយុ១៨ឆ្នាំគេឲ្យខ្ញុំធ្វើការ តាមភូមិ តាមឃុំចិនហាណាដើរទៅជាមួយនារីដូចថានៅភូមិ ណាជំរឿនក្រមុំៗចិនហាណា យើងនិយាយឥលូវ គេហៅក្រមុំៗជំរឿនថាក្នុងភូមិនេះក្រមុំ មានប៉ុន្មានអីចិនទៅ អីនៅធ្វើការជាមួយពួកស្រីៗទៅខ្ញុំនៅជាមួយគ្នាចិនទៅ ។

វិសាល ៖ ជំរឿនប្រជាជន?

ភី ៖ អត់ទេនៅធ្វើការឃុំហ្នឹង ។

វិសាល ៖ ឃុំ?

ភី ៖ ឃុំតែផ្នែកនារីអីចិនហាណា ផ្នែកនារីចិនទៅនៅ ។

វិសាល ៖ ធ្វើការនៅឃុំ?

ភី ៖ ចា!

វិសាល ៖ អ៎! ចឹងធ្វើការនៅឃុំហ្នឹងចឹងទៅឃុំហ្នឹងឈ្មោះអីដែរទៅឃុំហ្នឹង?

ភី ៖ ឃុំគោកព្រិចដដែលហ្នឹង ។

វិសាល ៖ ឃុំគោកព្រិចដដែល ហើយមេឃុំពីណាទៅកាលហ្នឹង?

ភី ៖ មេឃុំហ្នឹងពូហ្នឹងមកពីស្រុកលើដែរ ឈ្មោះពូណៃណា ។

វិសាល ៖ ពូណៃ?

ភី ៖ ពូណៃ មណ្ឌលហ្នឹង ។

វិសាល ៖ សព្វថ្ងៃពូណៃហ្នឹងនៅរស់ទេ?

ភី ៖ ពូណៃហ្នឹងមិនដឹងជាស្លាប់ជារស់ទេពួកគេអស់ហ្នឹង ទៅបាត់ៗ ទៅបាត់ទៅបែកគ្នាតាំងពីបែកហ្នឹងមក បែកគ្នាមិនដែលជួបគ្នាសោះ ។ អត់ដែលដឹងដំណឹងពីគ្នាសោះ ។

វិសាល ៖ ចុះមីង កាលហ្នឹងកាលសម័យហ្នឹង កាលណាគេនិយាយពីគណៈឃុំគណៈអីចឹងមានៗបីដូចថាមានច្រើនគ្នាត្រូវទេមីង?

ភី ៖ ចា!

វិសាល ៖ មានផ្នែកអីគេខ្លះដែរមីង មានចាំខ្លះទេ?

ភី ៖ គណៈឃុំគេហ្នឹង កាលហ្នឹងដូចថាគេឃុំគេហ្នឹង គេមានប្រធាន អនុប្រធាន សមាជិកចឹងមកណា ហ្នឹងគេមានចឹងទៅ ។ ហើយដូចថាយើងខាងនារីចឹង ផ្នែកមួយជាផ្នែកនារីចឹងទៅតែវាគ្មានតួនាទីដឹងព្ធរឿង កិច្ចការផ្ទៃក្នុងអីគេទេ ដឹងថាផ្លូវផ្នែកនារីដឹងថា យើងពិនិត្យតែរឿងផ្នែកនារីទៅនារីៗ ចឹងដើរដាំបន្លែនៅតាមភូមិទៅ ដាំតែបន្លែទេអាកាលនៅជំនាន់ខ្ញុំដឹកនាំនេះដាំបន្លែ ហើយ ដល់ក្រោយឡើងបានទៅកងចល័តហ្នឹង ។

វិសាល ៖ ចឹងចង់ជម្រាបចង់សួរមីងថា មានទេដូចថាមានខាងគណៈខាងភស្តុភារ ខាងឃុំ គណៈខាងទ័ព គណៈខាងអីទេ?

ភី ៖ ខ្ញុំអត់មានដឹងទេ អត់ដឹងទេអារឿងហ្នឹង ។

វិសាល ៖ អត់ដឹងទេ បាទៗ ។

ភី ៖ អត់ដឹងទេ ។

វិសាល ៖ ចឹងជាក់ស្តែងគឺមានមេឃុំ មានអនុ មានសមាជិកអីដូចមីងមានប្រសាសន៍ចឹង?

ភី ៖ ចា! មានចឹង មាន៣ហ្នឹងហើយដូចថាមានប្រធាននារី ប្រធានយុវជន ។

វិសាល : ប្រធាននារី ប្រធានពីណាទៅ?

ភី : ប្រធាននារីក្នុងឃុំគោព្រិចហ្នឹង កាលហ្នឹងខ្ញុំហ្នឹង ។ ហើយដល់ហើយយុវជនហ្នឹងឈ្មោះមឿនហ្នឹង មិនដឹងជាស្លាប់ហើយមិនស្លាប់ទេកាល ហ្នឹង ។

វិសាល : ប្រធាននារីគឺអ្នកមីង បាទ ហើយប្រធានខាងបុរសវិញប្រធានខាងយុវជនបុរសប្រុស?

ភី : ដឹងវាមិនដឹងជាមកពីស្រុកណាទេ អាហ្នឹងនោះ ។

វិសាល : ឈ្មោះអីទៅ?

ភី : ឈ្មោះមឿន ។

វិសាល : មឿន?

ភី : ចា!

វិសាល : មិនដឹងស្លាប់រស់ទេឥលូវ បាទ ចឹងនៅសម័យនោះធ្វើជាប្រធាននារីឃុំគោកព្រិច កាន់ៗហ្នឹងកាន់ខាងនារី...?

ភី : នារី ។

វិសាល : ថាយុវៗនារិហីកាលហ្នឹង?

ភី : ចា! យុវនារីហ្នឹង ។

វិសាល : ចាស់ៗអត់ទេ?

ភី : ចា! នារីហ្នឹងគេឲ្យយើងដើរធ្វើការហ្នឹងដូចថានាំតែនារីដាំបន្លែទេ ។ មិនឲ្យធ្វើអីទេខ្ញុំ ខ្ញុំមិនដែលដើរដេកនៅមន្ទីទេខ្ញុំដើរដេកតែជាមួយគេតាមភូមិហ្នឹង ។ ចុះទៅសប្បាយជាមួយក្មេងៗស្រីៗដូចគ្នាហា ។ ដល់ពេលប្រមូលគ្នាចឹងទៅ បានម៉ាភូមិៗ ៨-១០នាក់ចឹងទៅនៅបបួលគ្នាដេកលេងចឹង ទៅ ដល់ថ្ងៃក្រោយខ្ញុំទៅភូមិទៀតចឹងទៅៗប្រមូលគ្នាដាំបន្លែទៅដាំបាយដាំអីហូប សប្បាយតាមក្រោមតាមនាងនេះចឹងទៅបានហើយ ។

វិសាល : កាលហ្នឹងពីណាគេអ្នករើសមីងឲ្យធ្វើជាប្រធាននារីឃុំហ្នឹងទេ នៅចាំបានទេកាលហ្នឹង?

ភី : ពួកស្រុក ពួកគណៈស្រុកគេហ្នឹង ។

វិសាល : គណៈស្រុកគេណាទៅ អាចចាំឈ្មោះគាត់បានទេអ្នកមីង?

ភី : ខ្ញុំប្រាប់ពួកតាំគុំ ។

វិសាល : តាំគុំ?

ភី : តាទិត្យ ។

វិសាល : តាទិត្យ?

ភី ៖ យាយបូអីហ្នឹង ។

វិសាល ៖ អ្នកចាត់តាំងហ្នឹង?

ភី ៖ អើ!

វិសាល ៖ មីងមានដឹងទេថាបីបានចាត់តាំងមីងធ្វើជាចីនដោយសារតែមីងមានប្រវត្តិម៉េចអីដែរ?

ភី ៖ ខ្ញុំអត់ដឹងដែរ ។

វិសាល ៖ អត់ដឹងដែរ ។

ភី ៖ ចា! ពេលនៅមន្ទីហ្នឹងយាយហ្នឹងគាត់ខស្បាប់ឲ្យខ្ញុំនៅជាមួយគាត់អីចឹងហាណា ។

វិសាល ៖ យាយៗមួយណាទៅ?

ភី ៖ យាយបូហ្នឹង ។

វិសាល ៖ យាយបូ ។

ភី ៖ យាយបូគាត់ថាដេកពួនអីនៅកន្លែងជាមួយគាត់អីចឹងទៅ ។ ចឹងទៅដល់ហើយគាត់ឲ្យខ្ញុំហ្នឹងចេញធ្វើការចឹងទៅ ឯគាត់ឲ្យទៅតែថ្ងៃៗទេយប់ឡើងឲ្យមក កន្លែងវិញខ្ញុំមិនមកៗខ្ញុំនៅដើរលេងតាមភូមិហា ។

វិសាល ៖ អាហ្នឹងគឺនៅពេលមុនតែងតាំង គេតែងតាំងឲ្យមីងធ្វើជាប្រធាននារីគឺនៅជិតយាយបូ?

ភី ៖ នៅជាមួយពួកនៅតាមអង្គភាពហ្នឹង ។

វិសាល ៖ តាមអង្គភាព អូ ចឹងមីងស្គាល់គាត់ច្បាស់ទេ?

ភី ៖ ស្គាល់ច្បាស់ ។

វិសាល ៖ អូ! គាត់អ្នកស្រុកហ្នឹងដែរហី?

ភី ៖ អត់ទេ ។

វិសាល ៖ គាត់នៅណាដែរ?

ភី ៖ គាត់នៅអី...អ្នកៗនិយាយរួម អ្នកដែលដឹកនាំខ្ពស់ៗហ្នឹងអ្នកហ្នឹងគឺអត់ដែលមានអ្នកស្រុកនៅនេះមួយទេ ។

វិសាល ៖ បាទ! ចឹងមកពីស្រុកណាវិញ?

ភី ៖ មកច្រើនតែមកពីត្រាំកក់ហ្នឹង ។ អត់មានទេអ្នកដឹកនាំខ្ពស់ៗគ្មានទេ យើងគ្រប់គ្នានៅស្រុកកាលណាប្រធានភូមិប្រធានក្រុម ប្រធាននារីអីនាយអាយអីអត់មានទេ ដូចថាអ្នកនយោបាយនយោអីអត់មានទេ ។ ដូចថាគេប្រើការតិចតួចអីហ្នឹងណា ។ អាហ្នឹងគេឲ្យពួកយើងអ្នកស្រុកយើងហ្នឹងធ្វើហើយ ពួកអាគេមានមេគេធំដុំគេចាត់តាំង ការងារគេហ្នឹង

សុទ្ធតែមកពីស្រុកគេទាំងអស់ទាំងឃុំទាំងអីហ្នឹង ។ អត់មានអ្នកស្រុកនេះធ្វើប្រធានឃុំអីមួយទេ ។

វិសាល ៖ បាទ! ក្រៅពីធ្វើជាប្រធាននារីមិញ ក្រៅពីមីងមានប្រសាសន៍ក្រៅពីនាំនារីៗក្នុងភូមិទៅដាំបន្លែដាំអីហ្នឹង គេមានធ្វើអីក្រៅពីកិច្ចការហ្នឹងទេអ្នកមីង?

ភី ៖ អត់មានធ្វើអីទេ ។

វិសាល ៖ ចឹងនៅហ្នឹងរហូតទាល់តែដាច់ហ្នឹងហីអ្នកមីង?

ភី ៖ នៅរហូត នៅយូរចឹងគេដល់បែកកងចល័តដើរដឹកប្រឡាយជីកអីចឹងទៅហាណាហ្នឹងហើយដើរដឹកប្រឡាយ ដើរវែកប្រឡាយវែកអី វែកដីអីចឹងទៅជាមួយនារីៗចឹងទៅដើរស្ទូង ដើរច្រូតអីរុករើហើយឲ្យតែថាកន្លែងណាត្រូវការផ្សារនេះអីហ្នឹងយើងអាខ្លួនទទេរហ្នឹងទៅមុនគេចឹងហើយ កងចល័តចឹងណោះ ។

វិសាល ៖ បើកាន់នារីម៉ាឃុំអីចឹង អ្នកយុវនារីជំទង់ៗដែលក្រោមការគ្រប់គ្រងរបស់មីងហ្នឹងមានប្រហែលជាប៉ុន្មាននាក់ដែរទៅអ្នកមីង?

ភី ៖ ភ្លេចហើយច្រើនណាស់ ។

វិសាល ៖ ដូចថាអាចស្មានបានទេ?

ភី ៖ វាច្រើនដែរ ។

វិសាល ៖ ដល់ខ្ទង់រយអីដល់ខ្ទង់ពាន់ទេ?

ភី ៖ ខ្ទង់រយដែរហ្នឹង ខ្ទង់រយទេបើតាមឃុំបើស្រុកអីពាន់ ។

វិសាល ៖ អ៎! ឃុំៗហ្នឹងដល់ខ្ទង់រយដែរ?

ភី ៖ ចា!

វិសាល ៖ អាចស្មានទេថាប៉ុន្មានរយដែរ?

ភី ៖ អឺម! ខ្ញុំចាំមិនបានទេ ។

វិសាល ៖ អាចថាដល់៥០០ទេមើលទៅអ្នកមីង?

ភី ៖ មិនដឹងម៉េចទេ មិនដឹងប៉ុន្មានរយទេ ។

វិសាល ៖ ច្រើន?

ភី ៖ ចុះខ្ញុំដូចថា១៣ភូមិ ។

វិសាល ៖ ១៣ភូមិក្នុងហ្នឹងអ្នកមីង?

ភី ៖ ចា!

វិសាល ៖ អូ! ១៣ភូមិ ៗ អ្នកមីងពេលមីងធ្វើជាប្រធាននារីអីចឹងហាមីង ថ្នាក់លើអីដែលណែនាំនិយាយពីគោលនយោបាយ និយាយត្រូវប្រាប់កូនចៅចេះមួយៗអីមានដែរទេអ្នកមីង?

ភី ៖ ចំពោះពួកខ្ញុំ គេប្រជុំៗកាលហ្នឹងខ្ញុំមិនសូវយល់ដូចថាផ្នែកនយោបាយអីខ្ញុំមិនសូវដឹងទេ បើដឹងថាផែនការថាថ្ងៃហ្នឹងត្រូវទៅដឹកប្រឡាយត្រង់នេះៗ ត្រង់នោះអីហ្នឹងបានដឹង ៗ អារឿងនយោបាយគេដូចថានិយាយឲ្យដល់ ខ្ញុំនិយាយឲ្យដល់សន្តមហ្នឹងរឿងអីគេមិនចំហរទេ គេច្រើនលាក់ការណ៍ ៗ

វិសាល ៖ ច្រើនលាក់ការណ៍?

ភី ៖ ដូចថាយើងកម្រិតយើងត្រឹមប៉ុន្មានគេឲ្យដឹងតែកម្រិតហ្នឹងទេ អត់មានឲ្យយើងដឹងកម្រិតជ្រៅជាងហ្នឹងទៀតទេ ៗ គេអត់ទេ គេលាក់ការណ៍ម៉េចគេមានខលាក់ការណ៍គេចឹងគេដាក់ផែនការគេ គេលាក់ ការណ៍គេចឹងហើយហើយយើងគេឲ្យដឹងត្រឹមប៉ុន្មានដឹងតែត្រឹមប៉ុណ្ណឹងហើយ អត់មានបានដឹងទេ ៗ និយាយទៅនិយាយឲ្យដល់ទៅប៉ុល ពតហ្នឹងខ្ញុំអត់ស្គាល់អត់ដែលឮឈ្មោះផង ៗ ចា! អត់ដែលឮឈ្មោះទៀតខ្ញុំប្រាប់ ៗ បើថាខៀវ សំផន ហ៊ូ នឹក ហ៊ូ យន់ អៀង ធីរិទ្ធអាហ្នឹងស្គាល់ ស្គាល់តែឈ្មោះទេមិន ដែលឃើញរូបទេ ៗ ស្គាល់តែឈ្មោះទេ មិនដែលឃើញមុខទេ ៗ ស្គាល់ហ្នឹងស្គាល់តាមឯកសារទេ

វិសាល ៖ បាទៗ! តាមឯកសារណាដែរទៅមីង?

ភី ៖ គ្រាន់តែថាដូចថាអៀង សារី ដូចថាខៀវ សំផនអីហ្នឹង ប្រធានទូទាំងប្រទេស អីចឹងហាណា គេដាក់មកថាចឹងហា ៗ គេដាក់ថាចឹងទៅ ហើយអៀង ធីរិទ្ធហ្នឹងគេថាប្រធាននារីទូទាំងប្រទេសអីចឹងអាហ្នឹងដឹង ៗ ដឹងថាចឹងតែមិនដែលឃើញ ហើយក៏បានទៅដល់ជួបមុខគាត់អីអត់ទេ ៗ

វិសាល ៖ អត់?

ភី ៖ មិនស្គាល់ផង បានឮតែឈ្មោះ ៗ

វិសាល ៖ ឃើញតាមឯកសារ មីងមិញបានមានប្រសាសន៍ថាឃើញតាមឯកសារ ឃើញនៅតាមឯកសារនៅពេលហ្នឹងឬក៏ឯកសារពេលសម័យឥលូវៗនេះទេ?

ភី ៖ កាលណុង កាលហ្នឹងគេថាដូចថាអាពេលប្រជុំអីចឹងទៅគេលើកការប្រជុំហ្នឹងហា គេលើកចឹង ៗ អាពេលយើងប្រជុំចឹងគេលើកអំពីមេដឹកនាំក្នុងប្រទេសឈ្មោះនេះៗៗ ៗ ឈ្មោះនោះអីចឹងហាណា ៗ យើងដឹងតាមអាគេប្រាប់ថា ដូចថាឋានៈនេះឋានៈនោះចឹងគេប្រាប់យើងថាចឹងទៅ ៗ ហ្នឹងទៅវាដឹងតាមគេប្រាប់ឋានៈហ្នឹងទេ ៗ

វិសាល ៖ អាចៗចាំទេអ្នកមីងកាលហ្នឹងទៅប្រជុំនៅតាណាដែរ ហើយពីណាអ្នកមក អ្នកធំណាមកចូលរួមនិយាយប្រាប់ចឹងទេប្អូនក៏ម៉េចដែរ?

ភី ៖ ប្រជុំគេប្រជុំកាលជំនាន់ហ្នឹងគណៈតំបន់គេហ្នឹង ។

វិសាល ៖ គណៈតំបន់ហី?

ភី ៖ អើ! គណៈតំបន់គេ ៗ គណៈតំបន់គេហ្នឹងក៏ជួយប្រជុំ...ណែ៎ ដំបូងប្រជុំគេលាក់ការណ៍ដើរលាក់ម៉ាយប់ហ្នឹង ទៅមកៗហ្នឹងដើរតែមកដល់ម៉ាកន្លែងហ្នឹង ទៅដល់ម៉ាភ្លែតដល់ពេលភ្លឺហើយថាអុញ នៅកន្លែងជិតគេពន្លាងមិនឲ្យដឹងទេ ខ្មាចឡានមកទម្លាក់ដឹងកាលហ្នឹងគេសម្ងាត់គេមុនហា គេប្រជុំក្នុងព្រៃហា ។

វិសាល ៖ តែប្រជុំហ្នឹងប្រជុំក្រោយ៧៥ទេប្អូនក៏មុន?

ភី ៖ ចា! ក្រោយ៧៥ហ្នឹង ។

វិសាល ៖ គាត់នៅតែសម្ងាត់ទៀត?

ភី ៖ ចា! ហីមិនទេ មុនៗ៧៥ហ្នឹង នៅអាឡានហោះមកទម្លាក់អីហ្នឹង មានហ្នឹងកាលហ្នឹង ។

វិសាល ៖ ចឹងមីងដឹងពុំឈ្មោះខៀវ សំផន អៀង ធីរិទ្ធ អៀង សារីអីហ្នឹងគឺតាំងពីមុនជិតបែកភ្នំពេញមកម៉េ្ចះចឹង?

ភី ៖ ចា!

វិសាល ៖ គណៈតំបន់ហ្នឹងគណៈតំបន់ពីណាគេដែរអ្នកមីង?

ភី ៖ ឈ្មោះតាសោមហ្នឹង ។

វិសាល ៖ បាទ! តាសោម?

ភី ៖ ចា! ហ្នឹងហើយ អាហ្នឹងៗបានជួបគាត់អាហ្នឹងបានទៅប្រជុំអី ។

វិសាល ៖ បានឃើញគាត់?

ភី ៖ ហ្នឹងហើយ បានឃើញហើយអាហ្នឹងប៉ុនសាប់ពុថាស្លាប់តាំងពីជំនាន់ហ្នឹងម៉េ្ចះ ។

វិសាល ៖ បាទ! កាលហ្នឹងប្រជុំមិញមានប្រសាសន៍ថាក្នុងព្រៃៗនៅតំបន់ណា?

ភី ៖ នៅមន្ទីរនៅគេធ្វើមន្ទីរគេហ្នឹងហា ។

វិសាល ៖ បាទ! គេធ្វើមន្ទីរគេ?

ភី ៖ គេធ្វើមន្ទីរគេចឹងដូចថា កន្លែងណាមួយគេធ្វើមន្ទីរគេបើកកន្លែងប្រជុំចឹងមួយនៅក្នុងព្រៃដូចពាងសម្ងាត់ចឹងទៅ យើងទៅចឹងទៅហ្នឹងសុទ្ធតែលាក់ការណ៍លាក់អី ប៉ុនអាកាលហ្នឹងខ្ញុំដូចថាប្រជុំចេះតែទៅៗវាមិនដឹងសាច់រឿងសាច់ការអីទេ ។

វិសាល ៖ អាចចាំបានទេទៅពីមុនបែកហ្នឹងរហូតដល់៧៩ បានចូលរួមប្រជុំប៉ុន្មានដងដែរ?

ភី ៖ បានច្រើនដងដែរហ្នឹង ។ ដល់ពេលបែកហើយប្រជុំនៅ... ចុះប្រជុំរឿងគេប្រជុំដូចថាប្រជុំរឿងគេនៅតាមស្រុក នៅតាមអីហ្នឹង ប្រជុំចឹងដូចថាប្រជុំដាក់ផែនការឲ្យយើងធ្វើឧទាហរណ៍ដូចថាផ្លូវជីក ប្រឡាយណោះ នៅភូមិណាចឹងគេហៅទៅប្រជុំហើយ ។ គេហៅទៅប្រជុំចឹងដាក់ផែនការណ៍ឲ្យធ្វើហ្នឹងមានទៅផែនការណ៍ស្អី ។

វិសាល ៖ អ៎! មានដែលចូលរួមកិច្ចប្រជុំណាដែលឃើញមេធំៗមកដូចជា ដូចថាគណៈតំបន់អីហ្នឹងក្រៅពីកិច្ចប្រជុំមួយដែលអ្នកមីងមានប្រសាសន៍ហ្នឹងថាមានតាសោមអីមក មានដែលឃើញមានប្រជុំផ្សេងៗទៀតមានដែលឃើញមេធំអីចូលរួមទេ?

ភី ៖ មានទេ មានត្រឹមតាម៉ុក ។

វិសាល ៖ តាម៉ុក?

ភី ៖ អើ! កាលហ្នឹងទៅប្រជុំនៅតាកែវហើយប៉ិនរឿងតាម៉ុកហ្នឹងដែលទៅចូលរួមប្រជុំគាត់មួងនៅខេត្តតាកែវហ្នឹង ។

វិសាល ៖ បាទ! ឆ្នាំណាអាចចាំទេមីង បែកហើយក្លាមប៉ុក៏បែកហើយយូរ?

ភី ៖ បែកហើយយូរដែរហ្នឹង ខ្ញុំមិនដឹងទេខ្ញុំចាំមិនបានដែរ ។ កាលហ្នឹងពួកខ្ញុំហ្នឹងខ្ញុំធ្វើកងចល័តនៅតាមនៅស្រុកហ្នឹងហើយ មកធ្វើនៅស្រុកហ្នឹងហើយ កងចល័ត ។ ទៅច្រូតស្រូវច្រូតអីយប់នៅទល់ដែនយួន ។

វិសាល ៖ អូ! ទៅច្រូតស្រូវដល់ទល់ដែនវៀតណាមទៀត?

ភី ៖ ចា! ទៅម្តុំផ្សាម (សោម)ហ្នឹង កាលហ្នឹងមានហ៊ានទៅច្រូតថ្ងៃទេ យួនផ្ទោងដាក់ ។ ទៅច្រូតតែយប់ទេ ខ្ញុំនោះ ។

វិសាល ៖ កាលទៅប្រជុំជាមួយតាម៉ុកនោះ អាចចាំបានទេកិច្ចប្រជុំគេលើកឡើងនិយាយអំពីបញ្ហាអីខ្លះទៅអ្នកមីង?

ភី ៖ ចាំមិនបានទេ ខ្ញុំនៅដូចថាមនយល់សាច់ការ ដូចថាចេះតែទៅៗ ហើយត្រង់យល់សាច់ការគឺអត់យល់ហ្នឹងនឹងគេទេដូចថាគេអ្នកយល់គេយល់ បានថាគេយល់គឺថាគេប្រជុំអីចឹងគេឲ្យយើងនិយាយហា គេឲ្យយើងនិយាយហើយបើថាយើងអ្នកយល់គេនិយាយកើត ខ្ញុំអត់យល់អត់ឃើញមេក្រុមថយទៅក្រោយទៀត មិនដឹង ។ ជួនណាប្រជុំមិនស្តាប់ផងអាល័យតែគូសលេងគូសអីចឹងទៅណា ។ អាល័យគូសរូបលេងអីចឹងទៅ តែទៅស្តាប់ទៅមិនយកចិត្តទុកដាក់ទេ បើដឹងថាដូចថា ផែនការឲ្យទៅធ្វើនេះធ្វើនោះអីអាហ្នឹងដឹង គេថា

ទៅដីកប្រឡាយឬក៏ទៅច្រូតថ្ងៃច្រូតម្ដុំនេះ ថ្ងៃនេះទៅដីកប្រឡាយណោះ ។ អាហ្នឹងដឹងច្បាស់ណាស់ ។

វិសាល : ពេលទទួលផែនការមកហ្នឹងគឺដឹកនាំកូនចៅនារីៗ ទៅៗ ?

ភី : ចាៗ! ទៅៗ ។

វិសាល : អ៎! បាទ ក្នុងកងនារីហ្នឹងអ្នកមីងមានសុទ្ធតែប្រជាជនមូលដ្ឋានឬក៏មានអ្នកថ្មីក្នុងហ្នឹងដែរ?

ភី : កាលមុនមានអ្នកថ្មីខ្លះដែរហ្នឹង ។

វិសាល : ពេលគ្រប់គ្រងហា?

ភី : មានអ្នកថ្មីខ្លះដែរ ដល់ក្រោយទៅវាអត់មានទេម្ដងនេះគេបញ្ជូនអ្នកថ្មីហ្នឹងទៅកន្លែងផ្សេងហាណា ពីមុននៅជាមួយអ្នកថ្មីអ្នកចាស់អីជាមួយគ្នាហ្នឹង ។

វិសាល : អ៎! ពេលបែកហើយភ្លាមហ្នឹងមានអ្នកថ្មីអ្នកចាស់លាយគ្នាចឹងទៅ?

ភី : ចា! នៅជាមួយគាគ្នាហ្នឹង ។

វិសាល : ហើយបន្ទាប់មកអ្នកថ្មីហ្នឹងគេយកទៅណា មានដឹងពីណាគេអ្នកយកទៅទេអ្នកមីង?

ភី : ទេ ពួកគេជាថ្នាក់លើៗ មិនដឹងដែរ ។

វិសាល : តែៗ គេឧបមាថាគេចង់ ឧបមាដូចថាមីងៗ ជាអ្នកគ្រប់គ្រងនៅក្រុមហ្នឹងហើយ?

ភី : ចា!

វិសាល : បាទ! កងហ្នឹងហើយកងប្រធានហ្នឹងហើយកងនារីឃុំ ឧបមាថាគេចង់ស្នើរនារីដែលប្រជាជានថ្មីគេៗ មកប្រាប់មីងមុនឬក៏ម៉េចដែរ?

ភី : គេ... ។

វិសាល : អ្នកណារាយការណ៍ហ្នឹង?

ភី : គេដូចថា ចំពោះនៅចឹងគេនិយាយពីរឿងម៉ែឪ គេដូចនារីៗ ចឹងវាមិនមានម៉ែឪវានៅភូមិ ។

វិសាល : បាទ!

ភី : ដល់ហើយគេផែនការក្នុងភូមិហ្នឹង ចឹងហើយគេប្រាប់ថាឥលូវអ្នកណាពួកថ្មីចឹងឲ្យមកតាមផ្ទះវិញចឹងទៅ ។ ហ្នឹងហើយឲ្យមកនៅតាមផ្ទះវិញចឹងមក ។

វិសាល : ហើយ?

ភី : ហើយដល់នេះចឹងគេបញ្ជូនទៅនេះទៅណាអីខ្ញុំមិនដឹងដែរ ។

វិសាល : អ៎! ចឹងដល់ពេលគេប្រាប់ហើយថាគេស្នើរឲ្យប្រជាជនថ្មីគេត្រលប់មកវិញ ចាប់ចុចឈ្មោះឲ្យគេមកៗ?

ភី ៖ ចា! អើប្រាប់ទៅថាទៅផ្ទះវិញទៅ វាអង្គការ ។ អង្គការគេឲ្យទៅនៅតាមមូលដ្ឋានវិញ ចឹងទៅ ។

វិសាល ៖ អ៎! ប្រាប់ដើរទៅប្រាប់គេមួយចឹងទៅ?

ភី ៖ ចា! ប្រាប់ប្រជុំនាំគ្នាមកប្រជុំហ្នឹង ចុះហៅប្រជុំទៅមួយៗចឹងទៅ ចុះយើងធ្វើការមានប្រធានកង ។

វិសាល ៖ បាទ! មីងជាប្រធានគេចឹងដូចថាមានអនុប្អូក៏មានជាជំនួយការ មានជានិរសារអីទេ?

ភី ៖ មានៗ ដូចថាជាអនុអីចឹងទៅ មានជាប្រធានកងដាក់តាំឃុំតាមក្រុមអីចឹងទៅ ។ មានតើវាមិនអត់ទេ ។

វិសាល ៖ អ៎! ចឹងតាមមីងមានប្រសាសន៍ចឹងនៅក្នុងភូមិប្រហែលមានប្រធានកងមានប្រធាននារីហ្នឹងផ្សេងទៀត?

ភី ៖ ចា!

វិសាល ៖ នៅតាមភូមិ?

ភី ៖ ចា! តាមភូមិ ។

វិសាល ៖ ចឹងៗគាត់ទាំងអស់សុទ្ធតែជាអ្នកនៅក្រោមមីង?

ភី ៖ ចា!

វិសាល ៖ បាទ! ពួកគាត់ដូចថាមានដែលរាយការណ៍អីប្រាប់អ្នកមីងទេ ដូចថាអ្នកមីងជាមេគេចឹងហា?

ភី ៖ រាយការណ៍ហ្នឹងរាយការណ៍តែប៉ុណ្ណេះទេ ពួកនារីៗខ្ញុំថាអានេះវាមិនសូវធ្វើ អានោះមិនសូវធ្វើហើយខ្ញុំច្រើនតែសម្ងុតអាអ្នកនិយាយ ។ អាទៀតពេលមកដេកមកអស់កម្លាំងនិយាយប្រាប់ហើយថាថ្ងង់ណាស់ដេកទៅ តែប៉ុណ្ណឹង ខ្ជិលៗស្ដាប់ខ្ញុំមិនសូវកើតទុកជាមួយគេទេ ។ អារឿងថាចាប់កំហុសគេអីខ្ញុំមិនដែលថាចេះចាប់កំហុសគេអីទេ ប៉ុនថារឿងបញ្ហាការមិនចាប់កំហុសហ្នឹងក៏វានៅតែមានខុសដែរ វាមិនអត់ទេ ។

វិសាល ៖ ខុសអីខ្លះទៅអ្នកមីង បើតាមការសង្កេតរបស់មីងហា?

ភី ៖ ដូចឧទារណ៍ដូចថា ជួនណាយើងដូចថាឧទាហរណ៍ ។ ឧទាហរណ៍ដូចថាឥលូវហ្នឹងដែនការគេថាឲ្យប្រមូលមាសនារីៗហ្នឹងចឹងហាណា ។ ទៅដល់ចឹងទៅយើងហៅថាមកប្រជុំចឹងថាឥលូវឯងនាំគ្នា ដូចថាថ្ងៃ១០ចឹងឲ្យទៅផ្ទះម្ដង ថាថ្ងៃ១០អាណាមាក្រវិល អាណាមានខ្សែកយកទៅឲ្យម៉ែឪឲ្យអស់ប្រយ័ត្នតែនៅ គេយកអស់ហើយ ។ យើងប្រាប់គេចឹងទៅ

តាមការពិតដែនការគេៗថាឲ្យយើងប្រមូលយក ចឹងហាណា តែដល់ខ្ញុំៗមិនយក ខ្ញុំមិនដឹងជាយករបស់គេធ្វើអី កាលហ្នឹងវាអត់មានការ ស្រលាញ់មាស ស្រលាញ់ពេជ្រអីទេ អត់ដឹង ដល់ចឹងខ្ញុំថាឯងថ្ងៃទី១០ហ្នឹងនាំគ្នាទៅផ្ទះទុក មាសឲ្យអស់អាលីងកុំយកមកឲ្យសោះអញប្រាប់ថាខ្មែរកវាមិនមានក្រវិលពាក់ៗ ទាំងថ្មីទាំងចាស់ហ្នឹង ទៅក៏ទៅខ្ញុំមិនដែលទៅប៉ះពាល់របស់បងប្អូនណាទេ រឿងអាយករបស់របរហ្នឹង អីគេឲ្យនាឡិកាមួយដែរថ្មីហើយនឹងខ្ញុំលើកមកហ្នឹងទារវិញអាញ៉ែអាញ៉ែ ហើយដល់ឲ្យមកខ្ញុំៗអត់យកផង នាឡិកាហ្នឹងខ្ញុំឲ្យទៅពេទ្យៗគេធ្វើការមានម៉ោងមានអីៗ ខ្ញុំធ្វើការនេះខ្ញុំមិនបាច់មានម៉ោងមើលតែថ្ងៃទេៗ ហើយគេដាក់សារ៉ូមដាក់អីអ្នកជម្ងឺអីមានមកខ្ញុំឲ្យទៅគេទៅ ហើយដល់ហើយគេមកទារខ្ញុំថា ខ្ញុំឲ្យគេហើយខ្ញុំមានឯណាគេមកទារនាឡិកាវិញ មកខ្ញុំក្រវាត់ខោវាឡើងម៉ាសាហើយ បើថាខ្ញុំមានមាសវិញហ្នឹង ខ្ញុំមិនដឹងជាយ៉ាងម៉េចផង បើកាលហ្នឹងខ្ញុំយករបស់គេទេៗ

វិសាល : បាទ! ចឹងនៅក្នុងឃុំហ្នឹងសម័យហ្នឹងមាន១៣ភូមិ?

ភី : ចា!

វិសាល : ចឹងគឺថានៅក្នុងភូមិហ្នឹងមួយ មីងមានកូនចៅនៅហ្នឹងហើយ?

ភី : ហ្នឹងហើយៗ

វិសាល : អ្នកនៅក្រោមបង្គាប់មីង គេរាយការណ៍អីចឹងមកៗ នៅក្នុងកងហ្នឹងគឺពេលអ្នកមីងទទួលបញ្ជាពីៗខាងដូចថាពីដែនការថា ត្រូវទៅធ្វើនៅនេះកន្លែងនេះៗអីដូចថាត្រូវទៅលើកទំនប់តានេះ ចឹងមីងក៏ដឹកនាំគេទៅៗ?

ភី : ចា!

វិសាល : ពីណាគេមីងមានដឹងអ្នកណាគេជាអ្នកចេញដែនការឲ្យមីងទេ ឬក៏មានជាសំបុត្រមកឬមួយយ៉ាងម៉េចដែរ?

ភី : សំបុត្រគេមក ឧទារណ៍គ្នាគេៗប្រជុំចឹងហាថា ឧទាហរណ៍ផ្លូវថាប្រឡាយចឹងៗត្រូវទៅជីកនៅត្រង់នេះៗអីចឹងហាណា គេប្រជុំគ្នាគេហើយអស់ហើយប៉ិនថាយើងគ្រាន់តែទទួលដែនការត្រឹមម៉ាធ្វើហ្នឹងៗ

វិសាល : បាទ! ដែនការហ្នឹងមីងទទួលបាននៅក្នុងពេលប្រជុំឬមួយក៏គេយកសំបុត្រមកជូនអ្នកមីង?

ភី : ជួនណាប្រជុំ ជួនណាគេយកសំបុត្រមកទៅ ហើយជួនណាគេមកហៅចឹងទៅៗ

វិសាល ៖ បាទ! ហើយមីងក៏ដឹកនាំគេទៅៗ?

ភី ៖ ហ្នឹងហើយទៅៗ ក៏ប្រាប់គ្នាវែកអីៗទៅៗអាគេងអាទោងទៅ ។

វិសាល ៖ អ្នកមីងកាលហ្នឹងនៅមន្ទី នៅប្រធានមន្ទីមីងនៅខាងឃុំ?

ភី ៖ នៅខាងប្រធានមន្ទីហ្នឹក៏មន្ទីស្រុកដែរ តែដល់ពេលគេឲ្យខ្ញុំចេញធ្វើការហ្នឹង ធ្វើការត្រឹមតែម៉ាប្រមូលនារី នាំនារីដាំបន្លែដាំបន្ការដាំអីហ្នឹងតាមឃុំហ្នឹងទេ ។ ដល់យូរៗទៅគេឲ្យខ្ញុំចេញទៅៗ ចេញទៅហ្នឹងទៅស្រុកទៀតទៅណាចេញពីភូមិហ្នឹងដល់ យូរៗទៅហ្នឹង គេឲ្យចេញទៅទៀតទៅ ទៅធ្វើការនៅតាមស្រុកហ្នឹង ធ្វើការមិនបាន ប៉ុន្មានខែទេ នៅតិចខែដែរ ។

វិសាល ៖ តិចខែដែរ ហើយនៅម៉េចទៀតទៅតិចខែហ្នឹង?

ភី ៖ ដល់ហើយវាបែកចឹងទៅ ។

វិសាល ៖ អ៎! ចឹងដំបូងអ្នកមីងនៅធ្វើការឃុំ បន្ទាប់មកទៀតគេចាត់ឲ្យទៅដល់ស្រុក?

ភី ៖ ចា!

វិសាល ៖ អ៎! ស្រុកហ្នឹងបានឋានៈត្រឹមប៉ុណ្ណាដែរអ្នកមីង?

ភី ៖ នាំមេកងចល័តអាចឹងដដែលហ្នឹង ។

វិសាល ៖ អ៎! ចឹងៗខ្ញុំរាងអត់សូវច្បាស់ចឹង មុនដំបូងមេប្រធានឃុំនារី?

ភី ៖ ចា!

វិសាល ៖ បាទ! ហើយដល់ពេលទៅស្រុកប្រធានឃុំស្រុកចឹងហីអ្នកមីង ឬក៏មិនមែនទេ?

ភី ៖ ចា!

វិសាល ៖ អ៎! ប្រធាននារីស្រុក?

ភី ៖ ចា!

វិសាល ៖ អ៎!

ភី ៖ ប្រធាន អត់មានប្រធាននារីស្រុកទេ ប្រធាននារីៗហ្នឹងគេថាប្រធាននារីហ្នឹងគ្រប់គ្រងស្រ្តីៗទាំងអស់ណាទៅដល់នោះគេថាកងចល័ត ។

វិសាល ៖ កងចល័ត?

ភី ៖ អឹម! កងចល័ត ។

វិសាល ៖ អូ! ចឹងអ្នកមីងប្រហែលជាមេកងចល័តចឹង?

ភី ៖ អឹមៗ! កងចល័តវិញហើយបើថានៅឃុំហ្នឹងប្រធាននារីចឹង វាអាចពិនិត្យទាំងចាស់ទាំងក្មេងទាំងមេម៉ាយអីចឹងទៅណា ទាំងកុមារអីចឹងទៅណា ។

វិសាល ៖ បាទ! ហើយដល់ពេលចឹងទៅឡើងដល់មេ?

ភី ៖ អឹម! ហើយដល់ពេលឡើងទៅស្រុកចឹងវាអស់សិទ្ធិរឿងដឹងឮរឿងខាងមូលដ្ឋាននេះម៉េចៗ ហ្នឹងលែងដឹងរឿងទាំងអស់ហើយ ដឹងថានាំគ្នាដឹកតែប្រឡាយហ្នឹងទៅ បើគេប្រាប់ថាដឹកប៉ុន្មានម៉ែត្រចឹងទៅវាស់នាំគ្នាវាស់ដឹកចឹងទៅ ។

វិសាល ៖ ចង់សុំសួរពេលនៅឃុំម្ដង ពេលទៅស្រុកហ្នឹងមីងមានប្រសាសន៍ធ្វើនៅស្រុកបានតិចក៏ដាច់ក៏បែក?

ភី ៖ ចា!

វិសាល ៖ ជិនាន់ប៉ុល ពត ពេលនៅក្នុងឃុំហ្នឹងកូនចៅដែលអ្នកមីងកាន់ទុកផ្ទាល់មើលឃើញគ្រប់គ្រងផ្ទាល់មានប៉ុន្មាននាក់ដែរ?

ភី ៖ វាភ្លេចៗ

វិសាល ៖ ភ្លេចហើយ តែដូចថាចំនួនប្រហែលជាប៉ុន្មានដែរទៅអ្នកមីង?

ភី ៖ វា....ៗ

វិសាល ៖ អាចថា២០-៣០នាក់ទេ?

ភី ៖ ជាង១០០ៗ

វិសាល ៖ ជាង១០០?

ភី ៖ អឹម! ១០០ហ្នឹងមិននេះទេៗ

វិសាល ៖ តែបើនៅភូមិផ្សេងៗវាមានផ្សេងៗទៀតទៅ?

ភី ៖ ចា!

វិសាល ៖ អ៎! ជាង១០០នាក់ កូនចៅហ្នឹងមានដែលធ្វើអីឲ្យមានបញ្ហាទេអ្នកមីង?

ភី ៖ អត់ទេ ពួកខ្ញុំមិនដែលមានបញ្ហាអីទេ ដូចថាខ្ញុំច្រៀនប្រាប់គេចឹងហាណាដូចថាគេត្រូវធ្វើម៉េចផែនការណាដូចថាតាមដានអីចឹងយើងប្រាប់ញទៅថា កុំធ្វើចឹងទៅប្រាប់គេទៅជួនណាប្រាប់ទៅគេថាយើងខូចទៅ ជួនណាខ្លះគេថាមិនខឹងទៅ ខ្លះក៏គេខឹងទៅ ។

វិសាល ៖ អ៎! មានគេខឹងគេអីដែរ?

ភី ៖ វាចេះតែខឹងហើយវាមិនដែលមិនអត់ខឹងទេ ដូចថាយើងនាំគេធ្វើចឹងយើងផែនការខបមារថាផ្លូវគេត្រូវធ្វើឲ្យហើយណា កំណត់ប៉ុន្មានថ្ងៃប្រឡាយមួយខ្សែហ្នឹងហើយមកយើងមិនបន្ទុំគេឲ្យធ្វើៗ ម៉្លោះហើយគេខឹងហើយ អឹម ឲ្យគេធ្វើៗ

វិសាល ៖ គេខឹងយើងៗមានចេញជាអាការៈអីទេហី?

ភី ៖ អត់មានធ្វើអីទេស្រុក គ្រាន់តែថាកាលហ្នឹងវាមិនស្អីទេដល់សម័យឥលូវហ្នឹងក៏វាមាន ប្រដែនគ្នាចឹងដូចថាអ្នកខ្លះចឹងគេមាននិយាយបញ្ឆិតបញ្ឆៀងឪដងអីចឹង វាធម្មតាចឹង ហាណា ។

វិសាល ៖ បាទ!

ភី ៖ ប៉ុនខ្ញុំៗធ្វើមិនដឹងធ្វើមិនឮអី ណាថាអីថាទៅខ្ញុំសម្រេចចិត្តចូលស្រុកហើយ ។

វិសាល ៖ បាទៗ! ក្នុងកងអ្នកមីងដែលកាន់ប្រហែលជា១០០នាក់ជាងហ្នឹង មានអ្នកធ្វើការអីធ្លាក់ ខ្លួនឈឺធ្លាក់អីហ្នឹងមានធ្លាប់មានដែរអ្នកមីង?

ភី ៖ មានតើមាន ។

វិសាល ៖ ហើយចឹងទៅមានដែលបានបញ្ជូនទៅពេទ្យនៅជិតហ្នឹងអីទេ?

ភី ៖ ពេទ្យកាលហ្នឹងពេទ្យភូមិគេហ្នឹង ។ ពេទ្យភូមិឃុំគេហ្នឹងមានទៅ គ្រាន់ថាវាពេទ្យវាម៉េចបាន ល្អដូចសម័យឥលូវទៅ ។ កាលហ្នឹងថ្នាំអាច់ទន្សាយវិនបានស្អីទៅ ។ ហើយសូនថ្នាំស្លឹក ឈើស្លឹកព្រៃហ្នឹងបានអីថ្នាំល្អគ្នានថ្នាំសឺរ៉ូមថ្នាំអីទេ ។ បេសឺរ៉ូមហ្នឹងគឺថា ច្រើនប្រើទឹកដូងខ្ទី យើងអីវិនហ្នឹង មិនមានអីគួរឲ្យនេះទេ ។

វិសាល ៖ ដែលបានទៅពេទ្យហ្នឹងទេអ្នកមីង?

ភី ៖ ទៅ ។

វិសាល ៖ ទៅ?

ភី ៖ ទៅចូលចេញចូលៗហ្នឹង ។

វិសាល ៖ ទៅចេញចូលហ្នឹងខ្លួនឯងឈឺឬមួយក៏យ៉ាងម៉េច?

ភី ៖ ទៅចឹងទៅៗមើលពួកហ្នឹងឈឺចឹងទៅ ហើយចង់ទៅលេងពេទ្យទៅចេះតែទៅរកថ្នាំរកអីចឹង ទៅចេះតែទៅៗ ស្រេចចិត្តចឹងហា ។

វិសាល ៖ មីងស្គាល់គេនៅពេទ្យហ្នឹងទេ?

ភី ៖ ស្គាល់តើអ្នកធ្វើការប៉ុន្មានកាលជំនាន់ហ្នឹងស្គាល់គ្នាទាំងអស់ហ្នឹងហើយដល់ឥលូវ ភ្លេច ឈ្មោះអស់អាលីងហើយ គ្មានសល់ ។

វិសាល ៖ ចឹងអ្នកហ្នឹងឥលូវមិនមែនអ្នកនៅក្នុងភូមិនេះទេចឹង?

ភី ៖ គ្មានទេ គ្មាននៅនិយាយឲ្យដល់ស្រុកនេះគ្មានអ្នកធ្វើការសោះ គ្មានអ្នកធ្វើការធំៗទេជំនាន់ ហ្នឹង ។

វិសាល ៖ មានតែត្រាំកក់ទេអ្នកមីង?

ភី ៖ ហ្នឹងហើយមានតែគ្រាំកក់ទេ ក្រៅពីហ្នឹងអត់មានទេអត់មាន ស្រុកនេះបានប្រធានភូមិឡើងប្រធានឃុំអីអត់មានទេហើយដូចថាកងចល័តហ្នឹងក៏ចឹងដែរ កងចល័តហ្នឹងក៏គេយកពីស្រុកគេមកចឹងដែរ គេយកមកពីលើអីចឹងទៅដូចថាមកដល់ចឹងទៅគេបញ្ជាលើយើងចឹងដែរទៅណា ដូចថាខ្ញុំហ្នឹងនៅចឹងហើយមានគេនៅពីលើខ្ញុំចឹងទៀតទៅ ។

វិសាល ៖ បាទ! មីងថាជាធម្មតាពួកគាត់ឈឺដែរ តែភាគច្រើនហ្នឹងពួកគាត់ឈឺៗដោយសារមានមូលហេតុអីខ្លះដែរទៅអ្នកមីងចាំបានទេ?

ភី ៖ ទេមិនដឹងជាជម្ងឺស្អីៗ ចុះកាលហ្នឹងហូបមានទៅបានគ្រប់គ្រាន់អីឈឺហ្នឹងវាធម្មតាហើយបើថាជម្ងឺហ្នឹងមិនដឹងជាជម្ងឺស្អី ។

វិសាល ៖ កាលហ្នឹងបាយៗរួមកតើហីមីង?

ភី ៖ បាយរួម បបររួមហ្នឹងមានដែលមានបាយទេជំនាន់ហ្នឹង ។

វិសាល ៖ មីងជាមេគេ មងកងគេ មេកើយគេចឹងក្នុងឃុំចឹងមីងហូបជាមួយគេឬក៏ហូបផ្ទាល់ខ្លួន?

ភី ៖ ហូបជាមួយគេខ្លះទៅ ហូបដូនណាហូបក្រោយគេចឹងទៅ ។

វិសាល ៖ មិនមែនថាយើងនៅមានផ្ទះហា អត់ហូបនៅផ្ទះយើងខ្លួនឯងអត់ទេ?

ភី ៖ ដូនណាដូចថាបើមកនៅ យើងចេញពីធ្វើការចឹងដូចថាយើងមានកន្លែងយើងមួយចឹងហាណាកន្លែងយើងមួយហ្នឹងនារីហ្នឹងដូចថាចប់ការងារអីចឹងទៅមកកន្លែងមួយចឹង ខ្ញុំមានផ្ទះមួយទៅផ្ទះនារីៗហ្នឹងមួយចឹងទៅ មូលគ្នាចឹងទៅខ្ញុំដូនណាប៉ុនហូបបាយឆ្នាំងតែមួយចឹងទៅតែដូនណាគេដួចយកមកឲ្យហូបទៅ តែបបរហ្នឹងក៏បបរដូចគ្នាដែរតែយើងបានឆ្អែតជាងគេនិយាយឲ្យដល់ណា ។ យើងបានហូបឆ្អែតជាងគេ គេដួសបបរក្នុងមួយឆ្នាំងហ្នឹងទោះខ្លួនយើងអ្នកដឹកនាំគេហ្នឹង ក៏អត់ហ៊ានហូបបាយរឹងដែរ ដឹងនៅតែយើងលើដឹងក៏យើងមានទោសដូចតែគ្នាហ្នឹង ។ ដល់ចឹងទៅម៉្លោះហើយយើងនៅតែហូបដូចតែគ្នាហ្នឹង

វិសាល ៖ ប៉ុនគ្រាន់តែមីងហ្នឹងបានហូបបានឆ្អែតជាងគេ ។

ភី ៖ ហ្នឹងហើយគ្រាន់ថាយើងវាបានឆ្អែតជាងគេ ។

វិសាល ៖ មានកូនចៅអ្នកមីងហ្នឹងមានដូចថាអ្នកណាខ្លះឈឺធ្ងន់អាចថារហូតដល់ស្លាប់ដែរទេ មានទេអ្នកមីងមានទេកាលហ្នឹង?

ភី ៖ មានៗដូចថា មើល កាលហ្នឹងមានស្លាប់ម្នាក់ដែរអាហ្នឹងស្លាប់ឃើញជាក់ស្ដែងណាស់អាហ្នឹងនោះ ។

វិសាល ៖ អ៎! មីងឃើញជាក់ស្ដែង?

ភី ៖ អឹម! អាហ្នឹងស្ងាប់ហ្នឹងវាចេះគេឲ្យផ្ញើចម្ការនៅនៅគ្រួសចាស់ណោះ នឹកទៅបែបចាញ់កាលហ្នឹងមើលទៅ ។ ផ្ញើចម្ការហ្នឹងនៅគ្រួសចាស់ហ្នឹងផ្ញើដាំដំណាំដាំអី នារីគ្រប់ផ្នែកវាមាននារីហ្នឹងនៅដាំបន្លែទៅ ម៉ាផ្នែកហ្នឹងទៅ ម៉ាផ្នែកជីកប្រឡាយអីចឹងទៅណា វាមិននេះទេវាកងចល័តហ្នឹង ។

វិសាល ៖ កាលហ្នឹងមីងមានបានទៅជាមួយទេ ឬគ្រាន់តែឮគេប្រាប់មកទេកាលហ្នឹង?

ភី ៖ ទៅៗកន្លែងណាឲ្យតែនារីនៅកន្លែងណាខ្ញុំនៅកន្លែងហ្នឹងហើយ ។

វិសាល ៖ អ៎! ទៅតាមរហូត?

ភី ៖ ចា! ទៅតាមរហូតហ្នឹង ទៅជាមួយគ្នាស៊ីជាមួយគ្នាដេកជាមួយគ្នាហ្នឹងនៅតាហ្នឹង ទៅណាមកណាទៅតាជាមួយគ្នាទេក្រមុំនៅតែទាំងអស់គ្នាទេ ។

វិសាល ៖ អ៎! ចឹងកងហ្នឹងអាចថាកងក្រមុំ កងក្រមុំទាំងអស់គ្នាហ្នង?

ភី ៖ ចាៗ! កងក្រមុំ ។

វិសាល ៖ អូ! ចឹងកាលហ្នឹងកូនចៅអ្នកមីងអីមានដែលស្នើរសុំអ្នកមីងថា បងប្រធានខ្ញុំចង់ទៅលេងផ្ទះទៅលេងអីទេ?

ភី ៖ មានតើ ។

វិសាល ៖ មាន?

ភី ៖ មាន ។

វិសាល ៖ ច្រើនទេមីង?

ភី ៖ មានច្រើនតើថាជួនណាឲ្យខ្ញុំសុំទៅផ្ទះ ហើយអ្នកណាសុំអាចទៅបានក៏ទៅៗ អ្នកណាសុំមិនបានមិនឲ្យទៅៗចឹងទៅ ។

វិសាល ៖ បាទ! ករណីមិនឲ្យទៅហ្នឹងយ៉ាងម៉េច ឲ្យទៅហ្នឹងយ៉ាងម៉េចដែរ?

ភី ៖ ដូចថាគេប្រាប់ថា ឥលូវហ្នឹងម៉ែខ្ញុំឈឺហើយណា ។ ម៉ែខ្ញុំឈឺហើយ ឥលូវខ្ញុំទៅមើលម៉ែហើយ អាហ្នឹងទៅៗ ។

វិសាល ៖ ហើយអ្នកមីងអនុញ្ញាតឲ្យគេទៅៗ?

ភី ៖ ឲ្យគេទៅហើយ ដល់អាខ្លះដូចថា អាខ្លះដូចថាមនុស្សយើងវាមានខុសគ្នាអាខ្លះលួចរត់ទៅៗ មិនប្រាប់ទៅ ។

វិសាល ៖ ហើយលួចរត់ទៅហ្នឹងម៉េចខ្លះទៅហេតុការណ៍ហ៎?

ភី ៖ ដល់រត់ទៅដល់ហើយ អាអ្នកតាមក្រុមហ្នឹងគេទៅយកមកវិញទៅ ។

វិសាល ៖ អូ! ក្មេចសួរថាកងមីងហ្នឹងមានប្រុសៗធ្វើការនៅជាមួយទេមីង?

ភី ៖ អត់មានទេ។

វិសាល ៖ ចឹងសុទ្ធតែស្រីសុទ្ធហ្មង?

ភី ៖ សុទ្ធតែស្រីសុទ្ធ។

វិសាល ៖ អូ! ហើយដល់ពេលគេលួចរត់ទៅហ្នឹងធ្វើម៉េចទៅមីង?

ភី ៖ ទៅយកមកវិញហ្នឹងហើយ។

វិសាល ៖ ទៅយកមកវិញហ្នឹងក្រុមទៅយកខ្លួនឯងឬក៏ទៅប្រាប់ពួកឈ្លបពួកយោធាឲ្យទៅយក?

ភី ៖ អត់ទេ ទៅយកខ្លួនឯងមកហ្មង ពួកខ្ញុំមិនដែលមានឈ្លបមានអីមកតាមទេនិយាយឲ្យដល់។ អ្នកធ្វើការជាមួយខ្ញុំមិនដែលមានឈ្លបមានអីមកតាមទេ ហើយទៅស្មាក់ទៅអីដែរ។

វិសាល ៖ ទៅយកតាមហ្នឹងទៅដល់ផ្ទះគេហ្នឹងហ្មង?

ភី ៖ ទៅខ្លះជួនណាតាមផ្លូវអីចឹងទៅ ជួនណាវាទៅម៉ោយប់ពីរយប់អីទៅ ខ្ញុំធ្វើមិនដឹងធ្វើមិនឮខ្លះទៅ។

វិសាល ៖ ដល់ពេលសុំហូរហែអីចឹងគេអត់មានដេញដើងទាន់អីចឹងទេមីង អ្នកមកសុំច្រើនដងចឹងហា?

ភី ៖ ខ្ញុំអត់មានបានតាមដានគេអីផងហ្នឹងកាលហ្នឹង

វិសាល ៖ អ៊ំ! ចឹងអាពេលអ្នកលួចរត់ទៅ ពេលមកវិញមានរឿងអីកើតឡើងទៅ?

ភី ៖ មានទៅរឿងអី នៅធ្វើការធម្មតាវិញទៅ។

វិសាល ៖ ចុះអត់មានណែនាំមានស្អីទេ?

ភី ៖ គ្រាន់មកវិញប្រាប់ថា បើលើកក្រោយបើចង់ទៅអីប្រាប់ផងណា។ សួរថាឯងទៅមានការអី។ សួរថាឯងទៅមានការអី ជួនណាវាថាម៉ែខ្ញុំឈឺចឹងខ្ញុំមិនហ៊ានសុំចឹងទៅ ជួនណាប្អូនចេះប្អូន ចោះអីហ្នឹងគឺវានិយាយតាមរឿងរបស់វាទៅ។ គ្រាន់យើងពន្យល់ថាថ្ងៃក្រោយយើងកុំ ធ្វើចឹងយើងមកវិញយើងត្រូវប្រាប់ចេះចុះអីទៅ។ តែបើរឿងពាក់ព័ន្ធស្រាលវាមិនអត់ទេ។ ខ្ញុំមិនធានាថាខ្ញុំហ្នឹងវាធ្វើការជំនាន់ហ្នឹងល្អអីអត់ទេ។

វិសាល ៖ ចឹងពេលចឹងទៅមានដែលប្រជុំថារាយការណ៍ពីអីៗ ថាការងារយើងយ៉ាងម៉េចៗហើយការងារដល់ណាហើយមានដែលប្រជុំទេអ្នកមីង?

ភី ៖ ដែលតើអារឿងហ្នឹងគេតែងតែប្រជុំហើយ ប៉ុនយើងធ្វើការជាមួយគ្នាចឹងយើងមិនបាច់មករាយការណ៍អីទេ ។

វិសាល ៖ ចឹងមីងមេធំមេស្រុកធំៗអីគេមានដែលហៅមីងឲ្យទៅរាយការណ៍អីប្រាប់គេទេ?

ភី ៖ ប្រាប់ ហៅតើហៅប្រជុំគេសួរតើ គេថាយើងធ្វើម៉េចហើយបានដល់ណា ។

វិសាល ៖ គេមានណែនាំយើងអីទេ?

ភី ៖ ប្រាប់តើ ថាយើងត្រូវពង្រឹងត្រូវខំៗម៉េចទៀតចឹងហា ជួនណាទៅគេរាយការណ៍ប្រាប់ថាអ្នកនេះៗចាស់ៗហើយត្រូវមានដៃគូរអីចឹងទៅ គេត្រូវរៀបចំឲ្យមានដៃគូរអីចឹងហា ។

វិសាល ៖ ជួនណាគាត់មានដឹងថាដៃគូរគាត់មួយណាៗទេ?

ភី ៖ ជួនណាដឹងតើ គេស្រលាញ់គ្នាអីចឹងទៅ អ្នកខ្លះអត់មានដឹងទេ ជួនណាគេស្រលាញ់គ្នាចឹងទៅគេប្រាប់យើងចឹងទៅថាគេចង់រៀបការនេះនោះចឹងហាណា ។

វិសាល ៖ បាទ! ហើយមីងចេះតែជួយគេទៅ?

ភី ៖ អើ! ហ្នឹងហើយចេះតែជួយទៅ ពេលបានដឹងហើយចឹងខ្ញុំជាអ្នកសរសេរឈ្មោះបញ្ជូនឲ្យគេលើទៅ រៀបចំទៅ ។

វិសាល ៖ មានអ្នកសុំប្រកែកថាអត់ចង់បានទេអ្នកមីងឬក៏អត់ទេ?

ភី ៖ មានដែរហ្នឹង អាណាគេប្រកែកគេអត់យក គេប្រកែកទៅ ។

វិសាល ៖ គេប្រាប់ថាម៉េចទៅមីង?

ភី ៖ គេប្រាប់ថាបងខ្ញុំមិនយកទេចឹងទៅ ហើយយើងក៏មិនបង្ខំគេដែរចឹងទៅ ។

វិសាល ៖ បាទ! យើងអត់បង្ខំគេទេ?

ភី ៖ ហ្នឹងហើយ ពួកខ្ញុំៗមិនបង្ខំទេ តែគេអ្នកដទៃទេដែលគេបង្ខំហ្នឹងខ្ញុំមិនដឹងដែរ ។

វិសាល ៖ បាទៗ! ធ្វើនៅកងចល័តហ្នឹងរហូតដល់គេចាត់តាំងមីងឲ្យធ្វើជាប្រធានកងចល័តនៅស្រុកមីងមានប្រសាសន៍ថាមិញធ្វើតែម៉ាភ្លែតទេបានបែកមក?

ភី ៖ ហ្នឹងហើយ ។

វិសាល ៖ ចឹងបែកមកដែលវៀតណាមវៃចូលមកដល់ភូមិហ្នឹងនៅមុន៧៩អត់មានទេអ្នកមីង?

ភី ៖ ចា!

វិសាល ៖ គឺវៃចូលមកដល់៧៩គឺបែកមកកន្លែងហ្នឹង?

ភី ៖ ចា!

វិសាល ៖ ចឹងមីងពេលមីងឡើងមកធ្វើជាប្រធានកងចល័តតំបន់ចឹង អ្នកមីងមានអន្តរក្សអី ឬនិរសាអីតាមខ្លួនទេអ្នកមីង?

ភី ៖ មានតើ មានអាក្មេងតូចមួយហ្នឹងទុកគ្រាន់ចង់សរសេរសំបុត្រផ្ញើរទៅថ្នាក់ក្រោមថ្នាក់លើអីហ្នឹង ។

វិសាល ៖ អូ! ចឹងមាននិរសាដែរ?

ភី ៖ ចា! មានអាក្មេងតូចមួយហ្នឹង ។

វិសាល ៖ ធ្វើនៅហ្នឹងប្រហែលជាប៉ុន្មានខែដែរ បានវៀតណាមបុកចូលមកមានចាំទេមីង?

ភី ៖ មិនដឹងប៉ុន្មានខែទេខ្ញុំចាំមិនបានទេ ។

វិសាល ៖ ពេលវៀតណាមបុកចូលមកអ្នកមីងមានចាំទេ កាលហ្នឹងអ្នកមីងមានរត់ទៅខាងណាខ្លះទៅអ្នកមីង ពេលណាបានត្រលប់មកផ្ទះវិញ?

ភី ៖ ខ្ញុំរត់ទៅឆ្ងាយណាស់ ទៅជាមួយគ្រួសារខ្ញុំហ្នឹងកាលហ្នឹងខ្ញុំរៀបការហើយៗ ។

វិសាល ៖ អូ! រៀបការ?

ភី ៖ ចា!

វិសាល ៖ រៀបការឆ្នាំណាដែរអ្នកមីង?

ភី ៖ ឆ្នាំអាមុនបែកហ្នឹង ។

វិសាល ៖ ៧៨?

ភី ៖ មិនទេ អាមុនយួនបុកនេះ ។

វិសាល ៖ មុនយួនបុកចូល៧៩?

ភី ៖ ហ្នឹងហើយ អាមុនយួនបុកចូលហ្នឹងឥលូវគិតមើលកូនខ្ញុំច្បងហ្នឹងអាយុ៣០ជាងហើយគិតប៉ុណ្ណឹងមើលឆ្នាំមមែ ។

វិសាល ៖ ចឹងមីងប្រហែលជាការ៧៧ ៧៦អីហ្នឹង ។

ប្តី ៖ អត់ទេ ៧៨ហ្នឹងហើយ ។

វិសាល ៖ អូ! កាលហ្នឹងរៀបការហ្នឹងកាលហ្នឹងមិនមែនស្គាល់គ្នាណាហី គេចាប់ឲ្យទេមីង?

ភី ៖ កាលហ្នឹងខ្ញុំគេឲ្យការច្រើនគ្នាណាស់តែខ្ញុំមិនព្រមយក ។

វិសាល ៖ បាទ!

ភី ៖ ហ្នឹងហើយខ្ញុំមិនព្រមយកចឹងទៅ ដល់ម៉្ងោះហើយគ្រួសារខ្ញុំមានធ្វើអី គាត់នៅកងចល័តដែរហ្នឹងយើងមើលទៅគាត់រាងស្លូត ខ្ញុំព្រមយកគាត់មក ។

វិសាល ៖ អ៎! គាត់នៅកងចល័តៗ

ភី ៖ ចា!

វិសាល ៖ គាត់នៅកងចល័តរបស់មីងឬក៏...?

ភី ៖ អត់ទេ គាត់នៅអង្គភាពផ្សេងទេៗ

វិសាល ៖ ផ្សេងទេៗ

ភី ៖ ចា!

វិសាល ៖ អ៎! ហើយក៏ការទៅហើយដល់ពេលវៀតណាមបុកចូលមកក៏រត់ទៅជាមួយគាត់ទៅ?

ភី ៖ នាំរត់ៗ

វិសាល ៖ កាលហ្នឹងមានកូនហើយនៅ?

ភី ៖ ខ្ញុំទម្ងន់៧ខែៗ

វិសាល ៖ រត់ទាំងពេលទម្ងន់៧ខែហ្នឹង?

ភី ៖ ចា!

វិសាល ៖ អូ! រត់ទៅដល់ណាខ្លះទៅអ្នកមីង?

ភី ៖ រត់ទៅដល់ហួសភ្នំលះបង់ ទឹកស្អុយ ឆ្ងាយផ្អែកូនស្អីណាឆ្ងាយណាស់ៗ

វិសាល ៖ ហើយពេលណាបានសម្រេចចិត្តមកវិញទៅ?

ភី ៖ ដល់ទៅហ្នឹងទៅប្ដីខ្ញុំហ្នឹងគាត់គ្រុន ហើយខ្ញុំហ្នឹងរកអីហូបមិនបានបេះតែចូលព្រៃជ្រៅៗពេកដល់ហ្នឹងនឹកឃើញថាក៏សំរេចចិត្តនាំគ្នាពីរនាក់ប្ដីប្រពន្ធដឹកដៃដើរលែងរួចហើយគាត់ឈឺហាថាទៅផ្ទះវិញហើយ ឥលូវយើងមកវិញហើយងាប់ៗទៅថាចឹងហា ថាងាប់ៗទៅនឹកម៉ែនឹកឪណាស់ខ្ញុំមិនដឹងជាម៉េចខ្លះទេៗ ដូចបុណ្យចឹងហាណា អ្នករត់នៅក្នុងព្រៃហ្នឹងសុទ្ធតែមនុស្សនៅក្នុងព្រៃហ្នឹងសុទ្ធតែមនុស្សទាំងអស់ពេញមានកងទ័ព មានប្រជាជនទៅ មានពួកនេះសុទ្ធតែពេញក្នុងព្រៃហ្នឹង ទាំងអស់ ដល់ហើយចឹងខ្ញុំប្រាប់ដូចថាអ្នកស្គាល់គ្នាចឹង ខ្ញុំថាខ្ញុំទៅវិញហើយណា ខ្ញុំទៅផ្ទះ វិញហើយដល់អ្នកគេស្គាល់ខ្ញុំគឺថា អ្នកដែលធ្លាប់ធ្វើការជាមួយខ្ញុំហ្នឹងគេថា បងអឺយកុំទៅ តែទៅស្លាប់ហើយបងឯងគេរកតែអ្នកចឹង ថាអើបើស្លាប់ក៏មិនដឹងធ្វើម៉េចដែរហើយម្នាក់ មួយនោះថា ឥលូវបើបងឯងមិនហ៊ានចូលទៅដល់ស្រុកបងឯងឥលូវចូលមកដល់នៅផ្ទះខ្ញុំមកឲ្យតែបានទៅ ឲ្យតែបានគ្នាចុះមកវិញថាចឹង ហាណាដល់ហើយថាតែទៅៗឲ្យដល់ផ្ទះ ហើយខ្ជិលនៅណាស់ដល់ចឹងនាំគ្នាមកដល់មកហើយមួយៗគេថាចឹងបើបងឯងហ៊ានទៅ ខ្ញុំក៏ទៅដែរ មួយគេថាខ្ញុំហ៊ានមកគេ

មកៗ តាមច្រើននាក់ណាស់កាលហ្នឹងមកចំណោម ហ្នឹងគេឃើញខ្ញុំហ៊ានដាំងគេ ។ ដល់ពេលចុះមកគេនាំគ្នាមកព្រឹបហ្នឹង ។

វិសាល : មីងមានចាំឈ្មោះគេទេ?

ភី : អត់ទេអត់មានស្គាល់ឈ្មោះគេទេ ដូចថាកងទ័ពកងអីហ្នឹងគ្រាន់តែមិត្តភ័ក្រ្តខ្ញុំគេអ្នកស្គាល់ធ្លាប់ធ្វើការអីជាមួយគ្នាទេណា គេថាតែហ៊ានទៅស្លាប់ហើយដល់ខ្ញុំថាខ្ញុំទៅហ្នឹងស្លាប់អីស្លាប់ចុះ អាហ្នឹងតាស្លាប់ៗឯស្រុកណោះមិនមែនស្លាប់ព្រៃទេថាចឹងហា ។

វិសាល : ចុះដល់ពេលមក?

ភី : មកទៅ មកដល់ព្រៃពាក់កណ្តាលផ្លូវមកដល់ព្រៃកំពង់ស្ពឺហ្នឹងដល់រៀបថ្នល់ជាតិហ្នឹងនាំគ្នារើអាជីកអាគល់ល្ហុងគល់ចេកហ្នឹងហើយ នឹងអន្ទរអីតិចតួចហ្នឹងអាដំឡូងហ្នឹងនាំគ្នាដាំបាយស៊ីប៉ុន្មានគ្នាហ្នឹង ។ ដាំបាយស៊ីយួនព័ទ្ធ ខ្ញុំមិនទាន់ទាំងបានបាយហូបផងយួនព័ទ្ធទៅដល់ ភ្លុងកាំភ្លើងព្រឹបស្រឡាំងកាំង ដល់ហើយយួនឆែកយកអាលីងស្ពឺអីវ៉ាន់ខោអាវអានាឡិការអាស្ពឺៗអាសឺរ៉ុំងចាក់ថ្នាំអាស្ពឺៗយកអាលីងព្រឹបទៅ ។

វិសាល : មីងមានសឺរ៉ុំងចាក់ថ្នាំដែរ?

ភី : ប្តីខ្ញុំហ្នឹងពេទ្យកងចល័ត ។

វិសាល : អូ! ប្តីពេទ្យកងចល័ត?

ភី : ចា!

វិសាល : ពេទ្យៗមេគាត់ពីណាទៅ?

ភី : មេហ្នឹងប្រធានកងចល័តគេហ្នឹង ប្រធានពេទ្យគេហ្នឹងដូចថាគេពីស្រុកមកចឹងគេមានពេទ្យគេប្រចាំគេមួយក្នុងអង្គភាពហ្នឹងហា ។

វិសាល : ហើយចុះគាត់មេពេទ្យប្រធានគេ?

ភី : អត់ទេពេទ្យធម្មតាទេ ។

វិសាល : ដល់កាលមកហ្នឹងគេមកជាមួយមីងមានគ្នាប៉ុន្មាននាក់?

ភី : ជាង៣០នាក់ច្រើនណាស់ ដល់គេភ្លុងហ្នឹងដកយកអស់អាលីង ហើយកាលហ្នឹងខ្ញុំមានចានស្ពាយស្ពាបព្រាអីមកដល់ដូរអន្ទរគេហូប ហើយខ្ញុំចែកឲ្យពួកហ្នឹងមកជាមួយអីហូបទៅណាហូបជាមួយគ្នា ។

វិសាល : ហើយចឹងមីងមកហ្នឹងយូរប៉ុណ្ណាដែរបានមកដល់ស្រុកវិញ?

ភី ៖ អូ! កាលហ្នឹងយូរណាស់យូរខែណាស់ ដល់គេអាណិតខ្ញុំណាស់ព្រោះមកផងពោះពង់អីធំផងយប់ឡើងចូលភូមិគេមួយហ្នឹង ភូមិហ្នឹងគេចិត្តល្អណាស់គេដាំបាយឲ្យហូបដាំបាយម៉ាឆ្នាំងប៉ុណ្ណឹងឲ្យពួកខ្ញុំហ្នឹងទៅវាហត់ហូបបាយហ្នឹងមិនបាយច្រើនទេដល់ហើយគាត់ថា អឹមក្រុម នេះមកហូបបាយអត់បានច្រើនទេ តែបើក្រុមមុនៗវិញមកហូបបាយបានច្រើនណាស់ ។ ចុះពួកខ្ញុំមានអីដូរអង្ករហ្នឹងមានអីវ៉ាន់អីតិចតួចហ្នឹងដូរអង្ករគេ ហើយដាំបាយឲ្យហើយក្មេងៗហ្នឹង ហូបដែរហ្នឹងអាមួយមកជាមួយគ្នាហ្នឹង ។ គេមកអ្នកមកជាមួយគ្នាហ្នឹងមានប៉ុន្មានយើងឲ្យគេហូប ជាមួយគ្នាអីចឹងទៅ ។

វិសាល ៖ ចឹងបានដើររហូតមកដល់ផ្ទះមក?

ភី ៖ ដើរទៅ ដេកយកតាណាដេកយប់តាហ្នឹងទៅ ។

វិសាល ៖ ហើយឆ្លងទន្លេមកដល់ស្រុកនេះបានឆ្លងហី ឬក៏ឆ្លងនៅតាមផ្លូវ?

ភី ៖ ចា! មកដល់ៗស្រុកហ្នឹង ។

វិសាល ៖ បានឆ្លងទន្លេ?

ភី ៖ ចា! មកដល់ស្រុកហើយបានឆ្លង ដល់ពេលមកហ្នឹងឃើញពូមួយហ្នឹងគាត់នៅពេញហើយគាត់ក៏ដើរមកដែរ ដល់ពេលដើរមកជួបគាត់ហ្នឹងក៏សួរគាត់ទៅថាដល់ដែរខ្លាចអត់គាត់ថាអត់អីទេមកៗគេអត់មានធ្វើបាបយើងទេ ខ្ញុំថាខ្ញុំខ្លាច ។

វិសាល ៖ អ៎! មីងចឹងនៅខ្លាចដែរកាលហ្នឹង?

ភី ៖ ចា! នៅខ្លាចតើ ដល់ហើយគាត់ថាមកៗអត់អីទេ ដល់ចឹងទៅខ្ញុំគិតថាអើ បើថាងាប់ក៏ងាប់ទៅជ្រុលប៉ុណ្ណេះហើយខ្ញុំតាំងចិត្តហា ។ ដល់មកៗឃើញម៉ែក្មេកខ្ញុំហ្នឹងគាត់នៅតែម្នាក់ឯងទេ មានកូនតែមួយហ្នឹងហើយគាត់នៅ មកជាមួយប្រជាជនមុនហ្នឹង ហើយខ្ញុំមិនហ៊ានមកឲ្យមកកាត់ជាមួយគេជាមួយឯងមក ។ មកជាមួយគេអ្នកស្រុកអ្នកភូមិហ្នឹង ជាមួយគេជាមួយឯងមក ។

វិសាល ៖ ចឹងនៅខាងក្រៅភូមិប៉ុន្មានឆ្នាំប៉ុន្មានខែបានមកវិញ?

ភី ៖ នៅម៉ាខែទេមិនរាប់ឆ្នាំទេ ។

វិសាល ៖ នៅភូមិណាទៅ?

ភី ៖ អត់មានបានចូលទេ អត់ទាន់បានចូលភូមិគេទេមកៗដល់ស្រុកហ្នឹងរហូតមកហ្នឹង ។

វិសាល ៖ អ៎! តែគ្រាន់តែថាមុនមកដល់ហ្នឹងយូរ?

ភី ៖ យូរដើរ ចុះដើរមកហា ។

វិសាល ៖ បាទ! ដល់ពេលចុះដល់ភូមិទៅអ្នកភូមិមានថាម៉េចដល់មីងទេ?

ភី ៖ វាថាការថាហ្នឹងវាធម្មតាទេ ធម្មតាយើងធ្លាប់ធ្វើការធ្លាប់មានមុខមានមាត់ហើយមកទៅល្អេមល្អាមជាងគេហ្នឹងគេចេះតែនិយាយចេះនិយាយចុះឌីដងហ្នឹង ទៅសួងទៅអីហ្នឹងគេនិយាយចេះនិយាយចុះ វានិយាយមិនចប់មិនហើយទេប៉ុនខ្ញុំថា ខ្ញុំតាំងចិត្តថាខ្ញុំថាធ្វើម៉េចបើខ្ញុំវាត្រូវឆ្លងកាត់តាមសង្គម ខ្ញុំចេះតែធ្វើតាមទៅវាធ្វើម៉េចធ្វើទៅតែជួនពេលខ្លះតខ្លះដែរហ្នឹង ។

វិសាល ៖ បាទ! មីងគេប្រើពាក្យម៉េចខ្លះទៅបានធ្វើឲ្យមីងខឹងចឹងហាមីង?

ភី ៖ អូ! គេចេះតែជេរចេះតែដៀលទៅ ជួនណាខបមារថាខ្ញុំកូនង៉ែតខ្ទីចឹងនៅដេកលើភ្លើងចឹងគេមកឡើងផ្ទះជេរចឹងហា ថាពួកមីឯងនេះយកកូនដូចថាគិតកូនគេកង់ទ័ពចឹងវាតាមការពិតខ្ញុំមិនមែនអ្នកនាំកូនគេទៅទេ ខ្ញុំមិនដែលចាត់តាំងពួកទ័ពពួកអីទេប៉ុនគេៗមកជេរចឹងទៅ គេថាពួកមីងហ្នឹងធ្វើឲ្យកូនអញបែកគ្នា បែកចេះចុះអីហ្នឹង ។

វិសាល ៖ ស្លាប់អីចឹងទៅ?

ភី ៖ អត់ស្លាប់អីទេ កូនគេនៅរស់ហ្នឹង ។

វិសាល ៖ អ៎! គ្រាន់តែបែកគ្នា ។

ភី ៖ ខ្លះគេមកជេរចេះចុះទៅ អើ វាចេះតែមានហើយរាប់មិនអស់ទេអារឿងអាបញ្ហាហ្នឹងនោះ ។

វិសាល ៖ ពេលមីងមកវិញហ្នឹងមានដែលឮថាគេចង់សងសឹកអ្នកដែលធ្លាប់ធ្វើការឲ្យខ្មែរក្រហមអីហាមីងមានដែលឮទេ?

ភី ៖ ធ្លាប់ឮតើ ឃើញពូមួយពូអា....ធ្វើមេឃុំហ្នឹង បែបគាត់ចិត្តមិនដាច់ទឹកភូមិទឹកស្រុក ក៏មកៗធម្មតាយើងធ្វើការគេចេះតែរណបយើង ហើយគេស្រលាញ់បងចេះបងចុះ ៗ គេចេះតែលើកតំកើងយើងទៅថាយើងហ្នឹងវាល្អអស្ចារ្យ យើងហ្នឹងគេវាស្រលាញ់យើងពេញចិត្តដល់បែបគាត់នឹកឃើញថាបែបពួកហ្នឹងវានៅស្រលាញ់គាត់ចឹង ដល់ពេលហើយមកៗចឹងកាំបិតពូថៅគេ ស្នរគេឡើងចាក់ហ្នង ។

វិសាល ៖ កាលហ្នឹងគាត់ហ្នឹងឈ្មោះអីគេដែរមីង?

ភី ៖ ឈ្មោះណៃៗ ។

វិសាល ៖ ណៃ?

ភី ៖ ចា! កាលហ្នឹងគេឡើងមកហ្នឹងកាន់ពូថៅឡើងមកចាក់យកហ្នង ។

វិសាល ៖ ហើយឡើងមកយកកាំបិតពូថៅកាប់ហ្នឹង?

ភី ៖ អឺម ។

វិសាល ៖ ចឹងហេតុការណ៍ហ្នឹងមានកើតឡើងមកច្រើនទេ?

ភី ៖ ខ្ញុំឮសូរតែម្នាក់ហ្នឹងហើយ ឮសូរតែម្នាក់ហ្នឹងទេប៉ុនមិនបានឃើញផ្ទាល់ទេឮសូរគេនិយាយដែរទេ ។

វិសាល ៖ បាទ! មីងនៅសម័យហ្នឹងហា មានដែលដឹងឮពីការកាប់សម្លាប់ដែរទេនៅសម័យខ្មែរក្រហមហា?

ភី ៖ ដែលៗឮ ដឹងតែថាឮចឹងទៅតាមកងចល័តអីចឹងទៅឮថាអាខ្លះគេចាប់ម៉ែចឹងទៅ អាខ្លះគេថាចាប់បង ចាប់ឪអីចឹងទៅឬតាមកងចល័តហ្នឹងគេនិយាយចឹងហាណា ថាគេចាប់ទៅថាគេម៉េចៗអីហ្នឹង មិនដឹងជាម៉េចអីហ្នឹងខ្ញុំមិនដឹងទេ ។

វិសាល ៖ ចឹងមីងមានចាំហេតុការណ៍ណាមួយដែលមីងមានស្គាល់ឈ្មោះស្គាល់អីទេ?

ភី ៖ អត់ទេ ខ្ញុំអត់មានចាំទេមិនដឹងអ្នកណាមួយៗអីទេ ខ្ញុំមិនដឹងទេ ។

វិសាល ៖ អត់ដឹងទេ ។

ភី ៖ ខ្ញុំអត់ដឹងទេ ។

វិសាល ៖ ចុះអឺមានដឹងមូលហេតុអីទេថាគេចាប់យកទៅសម្លាប់អីមានដឹងមូលហេតុទេ?

ភី ៖ អត់ដឹងមូលហេតុអីទេ ខ្ញុំមិនបានដឹងរឿងមូលហេតុរឿងគេអីទេដូចខ្ញុំប្រាប់ចឹងថាក្នុងកិច្ចការហ្នឹងគេមិនឲ្យយើងខាងនារីហ្នឹងដឹងទេ គេដឹងតែផ្នែកគេៗហៅថាផ្នែករដ្ឋបាលគេហ្នឹង ។ យើងហ្នឹងយើងមិនមានបញ្ហាអី យើងមិនមានតួនាទីអីត្រូវដឹងរឿងការងារគេទេប្រទេសជាតិហ្នឹងគ្រាន់តែដឹងថារឿងដឹកប្រឡាយដឹកអីហ្នឹង ។

វិសាល ៖ ចឹងមានដែលឮពីអ្នកមន្ត្រីរាជការដែលធ្លាប់ធ្វើការនៅសម័យលន់ នល់អី លាក់ប្រវត្តិអីហើយដល់ពេលខ្មែរក្រហមដឹងចាប់យកទៅធ្វើបាប ធ្វើទារុណកម្មអីមានដែលឮទេអ្នកមីង?

ភី ៖ ឮតើ ឮមាន ។

វិសាល ៖ ឮគុកនៅណាទៅអ្នកមីង?

ភី ៖ នោះនៅប្រធាតុនោះ វត្តប្រធាតុ ។

វិសាល ៖ វត្តប្រធាតុ?

ភី ៖ នៅហ្នឹងដែរប៉ុនខ្ញុំមិនដែលហ៊ានទៅទេ ។ ។

វិសាល ៖ មេៗគុកវត្តប្រធាគុហ្នឹងឈ្មោះអីដែរមានដឹងទេមីង?

ភី ៖ អឹម ឈ្មោះអីទេតាហ្នឹង...មិនដឹងទេនៅវត្តប្រធាគុហ្នឹងមិនដឹងឈ្មោះអីទេខ្ញុំភ្លេចដែរហើយ ខ្ញុំភ្លេចហើយមិនដឹងឈ្មោះអីទេ ។

វិសាល ៖ បាទ! ចង់ជម្រាបសួរអ្នកមីងថាមីងនៅទីនេះតាំងពី៧៩មកហើយ អ្នកមីងមានដឹងពីរឿង វត្តបុរាណ ជាក់ស្តែងវត្តនៅកជិតនេះដឹងថាមានរឿងអីកើតឡើងចំពោះវត្តនេះដែរទេ គេទុកចោលដដែលឬក៏គេ?

ភី ៖ ទុកចោលនៅហ្នឹង ។

វិសាល ៖ កាលហ្នឹងគេអត់មានបំផ្លាញអីទេ?

ភី ៖ អត់ទេអត់មានបំផ្លាញអីទេ វត្តនេះខ្ញុំដឹងតាវត្តហ្នឹងស្គាល់តែវត្តហ្នឹងមួយ ហើយវត្តព្រៃជើង ហ្នឹងអាហ្នឹងវាគ្មានធ្វើអីទេវត្តហ្នឹងនៅតែចឹងដដែល ។

វិសាល ៖ អត់មានដូចថាវៃរលំដួងអីអត់ទេ?

ភី ៖ អត់ទេ អត់មានទេ ។

វិសាល ៖ បាទ! មានដែលដឹងឮពីតុលាការខ្មែរក្រហមទេអ្នកមីង?

ភី ៖ អត់ដឹង ។

វិសាល ៖ តាំងពីឆ្នាំ២០០៦-២០០៧-២០០៨មកដែរឮពីតុលាការអីទេ?

ភី ៖ ឮៗដូចថាមានតុលាការគេកាត់ទោសខ្មែរក្រហមអីហ្នឹងខ្ញុំឮដែរ ។

វិសាល ៖ ឮៗតាមរយៈអីទៅ?

ភី ៖ តាម... ។

វិសាល ៖ វិទ្យុ ឬក៏ទូរទស្សន៍ មានទាំងពីរ?

ភី ៖ (សើច) ។

វិសាល ៖ កាលហ្នឹងឮបើកទៅប៉ុស្តិ៍នឹងដោយចៃដន្យទេ ឬមួយក៏តាមដានដែរ?

ភី ៖ បើកស្តាប់រាល់ថ្ងៃ ស្តាប់ធម្មតាចឹង មិនដែលទំនេរទេ បើមិនអស់ពីទូរទស្សន៍ វិទ្យុៗ ទូរទស្សន៍ទាំងយប់ទាំងថ្ងៃនឹង ទាល់តែគេដេកលក់ ជួនណាមិនទាន់បិទផង ។

វិសាល ៖ ដឹងច្រើនដែរពីរឿងតុលាការនឹង?

ភី ៖ ចា!

វិសាល ៖ បាទ! ចឹងដឹងប៉ុនណា មីងអាចជួយប្រាប់ផងបានទេ?

ភី ៖ ដឹងថាគេកាត់ទោសខ្មែរក្រហម គេកាត់ទោសមេធំៗនឹង ។

វិសាល ៖ ពីណាខ្លះទៅមេធំៗ?

ភី ៖ ដឹងពីណាគេថាលោកស្មីនៅគុកទួលស្លែងនឹង ។

វិសាល ៖ ឌុច កាំងហ្គេចអ៊ាវ?

ភី ៖ អឺ! អានឹងហើយ អៀង សារី, អៀង ធីរិទ្ធ អីនឹងហើយ ។

វិសាល ៖ ចុះខៀវ សំផន ពូទេ?

ភី ៖ ដូចពូ ហើយមិនពូទេ ចាំមិនអស់ដែរ ខ្ញុំតែចាំប៉ុន្មាន ខ្ញុំថាប៉ុននឹង ។

វិសាល ៖ ម៉េចដែរ មីងពូពីការគាំទ្រការកាត់ទោសនឹង យល់យ៉ាងម៉េចដែរ គាំទ្រទេ យល់ការកាត់ទោសនឹងវាល្អទេ ឬក៏យ៉ាងម៉េចដែរសម្រាប់អ្នកមីង?

ភី ៖ សម្រាប់ខ្ញុំមិនអាចវិនិច្ឆ័យកើត ព្រោះមិនដឹងវាម៉េចអីម៉េច អាក្រក់ល្អអីខ្ញុំមិនអាចវិនិច្ឆ័យបាន ។

វិសាល ៖ ខ្ញុំចង់សួរថាគាំទ្រការកាត់ទោសនឹងទេ ឬក៏អត់គាំទ្រទេ ឬគាំទ្រយ៉ាងម៉េចដែរ?

ភី ៖ ខ្ញុំតាមដំណើរអត្ថការ ខ្ញុំរឿងគាំទ្រធ្វើអីក៏ ព្រោះអីខ្ញុំតាំងចិត្តមកនៅកន្លែងនេះហើយថាធ្វើអី ក៏ខ្ញុំធ្វើតាមរបបនេះទាំងស្រុកតែម៉ង ។ ខ្ញុំមិនមានប្រឆាំង ធ្វើអីក៏មិនប្រឆាំង ។

វិសាល ៖ ខ្ញុំសូមអរគុណអ្នកមីងច្រើន ក្រែងលគ្នាខ្ញុំគាត់ចង់មានសំនួរខ្លះសួរអ្នកមីង ។

គន្ធី ៖ មីងនៅក្នុងភូមិមីង មានដែលគេខុសសីលធម៌ទេ?

ភី ៖ មុំភូមិខ្ញុំអាពេលនឹងគ្មានទេ បើគេពូសួរផ្សេងៗហើយគេមានដែលជំនាន់នឹង ។

គន្ធី ៖ គេផ្សេងមានម៉េច?

ភី ៖ មានដូចថាមើលនិយាយឲ្យដល់ មានដូចថាខាងឃុំគេផ្សេង ក្នុងឃុំនេះអត់មានទេ ប៉ុនដូចមេឃុំអីចឹង កាលជំនាន់នឹង មេឃុំគេស្រឡាញ់ពេទ្យ ស្រឡាញ់ប្រធាននារីភូមិគេស្រឡាញ់ ។ ដល់ពេលចឹងទៅគេចាប់យកទៅ ដឹងចាប់យកទៅណា ។

វិសាល ៖ អាចចាំឈ្មោះគេទេ?

ភី ៖ ចាំតើពួកឈ្មោះអី ឈ្មោះ តាញ៉ៅប ប្រធានឃុំកំពែងខ្ញុំ គាត់ទៅបែបសម្លាប់ក៏មិនដឹង ។

គន្ធី ៖ ចឹងមីងការមីងធ្វើការនៅស្រុក ក្រោយមកជិតបែក កាលនឹងមានសមាជិកក្នុងក្រុមមីងប៉ុន្មាននាក់?

ភី ៖ មិនដឹងប៉ុន្មាន ភ្លេចហើយ ។

គន្ធី ៖ តាមមីងស្មាន?

ភី ៖ ស្មាននឹងវារាប់ពាន់ដែរនឹង ។

កន្ទី ៖ ប្រហែលជាប៉ុន្មានខែ មីងធ្វើការនៅស្រុក?

ភី ៖ ដឹងប៉ុន្មានខែដែលទេ ។

កន្ទី ៖ មុនបែកប្រហែលជាប៉ុន្មានខែ មុនវៀតណាមចូល?

ភី ៖ ចាំមិនបាន វាយូរដែរនឹង មិនមែនថាមិនយូរ ប៉ុនមិនដឹងថាប៉ុន្មានខែ ធ្វើប្រឡាយបាន ច្រើនដែរ ។

កន្ទី ៖ ធ្វើនៅណាខ្លះដែរ?

ភី ៖ ធ្វើនៅយួនសែនទៅ ធ្វើស្ពីដីបេ្តរទៅអាទឹងស្ទួងនៅនឹង ហើយប្រឡាយខាងបៀតកោះ ត្រសសរនេះ ថាប្រឡាយស្ពីបារ អូរអំបិល សន្ទុងអី ប្រឡាយធម្មតាខ្វាត់ខ្វែងតូចធំ ។

កន្ទី ៖ ច្រើនដែរ?

ភី ៖ ចាំ!

កន្ទី ៖ ហើយពេលមីងចូលដល់ស្រុកចិន ដាក់ផែនការធ្វើការផ្សារអី មីងដាក់ផែនការខ្លួនឯង ឬ មួយក៏មានផែនការ?

ភី ៖ ផែនការពីគេមក យើងមានដឹងផែនការអីគេឲ្យធ្វើៗទៅ ។

កន្ទី ៖ គេឲ្យធ្វើម៉េចខ្លះទៅ?

ភី ៖ ឲ្យធ្វើគ្មានស្អីកាលនោះឲ្យធ្វើរឿងជីកប្រឡាយ ជីកអីនឹង មិនមានទៅធ្វើអីពួកនារីៗ ។

កន្ទី ៖ នារីៗនឹងមកពីខាងណាវិញ?

ភី ៖ នៅស្រុកនឹង ស្រុកគិរីវង់ ។

កន្ទី ៖ មានគេអ្នកជម្លៀសប្រជាជនថ្មីៗ?

ភី ៖ ថ្មីៗគេបញ្ជូនចេញអស់ហើយ កាលជំនាន់ឡើងទៅធ្វើការនៅនឹង ។

កន្ទី ៖ បញ្ជូនទៅណាវិញ?

ភី ៖ អត់ដឹង គេឲ្យទៅនៅផ្សេង ដូចជាពួកកម្ពុជាក្រោមអី មកមូលគ្នាមក ។

កន្ទី ៖ កម្ពុជាក្រោមគេយកមកពីណាមក?

ភី ៖ ដឹងគេហៅកម្ពុជាក្រោមៗចឹង ដឹងមកពីណាទេ ខ្ញុំទៅអីឡានគេធំៗមក គេដឹកមនុស្សចឹង មក ។

កន្ទី ៖ អ្នកណាគេឲ្យយកទៅដែរ?

ភី ៖ ពួកគេ មិនដឹងជាផែនការគេពីណាមក ខ្ញុំមិនដឹងដែរ ។

កន្ទី ៖ ច្រើនទេមីង កាលនឹងកម្ពុជាក្រោមប្រហែលជាប៉ុន្មាននាក់?

ភី ៖ កម្ពុជាក្រោម អ្នកថ្មី អ្នកអីគេនឹងនៅមូលគ្នានឹង ដឹងប៉ុន្មានមិនបានរាប់ ។

គន្ធី ៖ កម្ពុជាក្រោមគាត់ទៅជាមួយអ្នកថ្មី?

ភី ៖ អឺ! អានឹងនៅភូមិ ។

គន្ធី ៖ ពួកនឹង ធ្លាប់នៅជាមួយក្រុមមីងទេ?

ភី ៖ នៅកាលនៅឃុំនឹង នៅធ្វើការ តែយើងមិនសូវបានជិតដល់ស្គាល់អីប៉ុន្មានណាស់ណាទេ ហើយអារឿងក៏ខ្ញុំថាធ្វើការៗដូចជាវាមិនដឹងជាច្បាស់លាស់រឿងអីមួយដែរ និយាយឲ្យដល់ ។

គន្ធី ៖ ច្បាស់លាស់ យ៉ាងម៉េចទៅមីង?

ភី ៖ ដូចថាផែនការស្អី មិនដឹងស៊ីជំរៅក្នុងកិច្ចការផ្សេងៗ ហើយផែនការគេទៅមុខទៀត ខ្ញុំមិនដឹងទេ ។ ដឹងតែថាប្រឡាយៗ ដឹងតែថាទំនប់ៗ ។

គន្ធី ៖ ធ្វើការម៉េចដែរមីង ហត់ទេ បើតាមចិត្តមីង?

ភី ៖ ហ៊ើ! ហត់ មកកំណត់ម៉ោងកំណត់នេះ ។

គន្ធី ៖ ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ភី ៖ ពីម៉ោង៧ ដល់ម៉ោង១១នឹង ពីម៉ោង២ដល់ម៉ោង៥ ដួនណាធ្វើការយប់ទៀត ។

គន្ធី ៖ ពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

ភី ៖ តាមដូចថាគេចែកប៉ូស្តិ៍ឲ្យចឹង អាណាគេធ្វើលឿនគេហើយគេឈប់ទៅ អាណាគ្នាធ្វើយូរចេះតែធ្វើទៅ ។

គន្ធី ៖ ទោះជាចប់ម៉ោងការងារក៏ដោយ?

ភី ៖ អឺ! ស្រេចតែគេ ទៅគេដាក់ផែនការ ម៉ាក្រុមនេះប៉ុន្មានម៉ែត្រ ក្រុមនេះប៉ុន្មានម៉ែត្រ ។

គន្ធី ៖ ហើយមានអ្នកដែលធ្វើមិនហើយ?

ភី ៖ ធ្វើ វាអត់មិនហើយទេ គ្រាន់វាយូរ រឿងហើយមិនហើយទេ បើមិនហើយក៏ត្រូវតែធ្វើឲ្យហើយដែរ ។

គន្ធី ៖ ចុះបើធ្វើមិនហើយវិញ គេមានខាងក្រុមចឹង មានធ្វើម៉េចជាមួយក្រុមនឹង ដែលធ្វើមិនហើយ?

ភី ៖ អត់ គ្រាន់តែថាឲ្យធ្វើឲ្យហើយ ។

គន្ធី ៖ ចុះបើថាធ្វើអត់ឲ្យហើយ ស្អែកឡើងគិតម៉េចទៀតទៅ?

ភី ៖ ស្អែកឡើងធ្វើទៀតទៅ ។

គន្ទី ៖ ដូចថាមិនជួយគ្នាក្នុងក្រុមធ្វើឲ្យហើយ?

ភី ៖ ជួនណាគេជួយដូចថាគ្នាគេចឹង អាស្រ័យទៅគេយល់គ្នា ជួយគ្នា ។

គន្ទី ៖ ប្រជាជនកម្ពុជាក្រោមគេមកៗ?

ភី ៖ មកដូចជំនាន់នឹង ដូចវានៅពួកភ្នំពេញចឹងដែរ ដល់ពេលរំដោះមក នៅទីក្រុងភ្នំពេញវាមានគ្រប់ជាន់ជាតិ ។ ដល់ពេលមកណាត្រូវមកខាងនឹងមក ណាទៅខាងនោះទៅនោះ ។

គន្ទី ៖ កម្ពុជាក្រោម គេយកពីភ្នំពេញមកវិញ?

ភី ៖ ភ្នំពេញ វាចេញពីភ្នំពេញដូចតែគ្នា គ្មានមកពីណា ។

គន្ទី ៖ ចុះម៉េចគេហៅកម្ពុជាក្រោម មិនមែនគេហៅពួកអ្នកថ្មី?

ភី ៖ អ្នកថ្មី ក៏គេហៅ អ្នកថ្មីជួនណាផ្ទះគេមកនៅកម្ពុជាក្រោមអ្នកថ្មីដែរ ប៉ុនគេថាផ្ទះគេនៅកម្ពុជាក្រោម ។

គន្ទី ៖ ផ្ទះគេនៅកម្ពុជាក្រោមយ៉ាងម៉េច ដូចថានៅភូមិ ឬក៏នៅជាក្រុម?

ភី ៖ នៅភូមិ មិនដឹងជាស្អី គេហៅកម្ពុជាក្រោម គេថាដូចជាសញ្ជាតិកម្ពុជាក្រោមចឹងណា ។

គន្ទី ៖ តែភាគច្រើន កម្ពុជាក្រោម គេហៅខ្លួនឯងកម្ពុជាក្រោម?

ភី ៖ អឺ! គេហៅខ្លួនគេកម្ពុជាក្រោម ដូចថាយើងសញ្ជាតិខ្មែរ គេដាក់សញ្ជាតិគេកម្ពុជាក្រោម ។

គន្ទី ៖ ពួកគាត់មកពីខេត្តណាវិញ តំបន់ណាវិញ?

ភី ៖ ដឹង មកពីភ្នំពេញ ណាដឹងគេមកពីណា ។

គន្ទី ៖ គាត់នៅ មកនឹងបានរយៈពេលប៉ុន្មានដែរ?

ភី ៖ មិនដឹងប៉ុន្មានទេ ខ្ញុំមិនចាំ ។

គន្ទី ៖ ប្រហែលជាប៉ុន្មាននាក់ដែរមីង ដែលពួកគាត់មក?

ភី ៖ ហ៎! រាប់ច្រើនដែរនឹង វាច្រឡូកច្រឡំគ្នាជាមួយខ្មែរយើងមិនកម្ពុជាក្រោមៗដូចតែគ្នា មិនថា ណាជាណៃដូចតែគ្នា គ្រាន់តែគេប្រាប់ថាកម្ពុជាក្រោមចឹងទៅ ។

គន្ទី ៖ ហើយចុះកម្ពុជាក្រោមចឹង គេបញ្ជូនទៅនឹងទៅតែ?

ភី ៖ បញ្ជូនទៅជាមួយពួកអ្នកថ្មីនឹង ទៅណាអីណាគេទេ ទៅស្រុក ឮថាទៅម្ដុំគេហៅស្អី ទៅនៅនឹងដែរ ទៅនៅស្រុកលើ គេហៅស្រុកលើកាលជំនាន់នឹង ។ តែទៅនឹងគេហៅស្រុកលើ គេថាទៅនៅស្រុកលើ ប៉ុនមិនដឹងនៅណាទេ ។

គន្ទី ៖ ហើយគេឲ្យទៅធ្វើអីដែរ?

ភី ៖ ទៅធ្វើការធ្វើស្រែធ្វើចំការអីធម្មតាដូចតែនៅចឹង គ្រាន់តែថាបញ្ជូនទៅមានកន្លែងគេនេះ នៅផ្សេង នោះនៅផ្សេង ។

គន្ធី ៖ ចុះការគ្រប់គ្រងមីងនៅនេះចឹង ដូចថាវាចូលរាប់ពាន់មនុស្ស ដូចថាផលវិបាកអីមាន ម៉េចដែរ ចំពោះមីងគ្រប់គ្រង?

ភី ៖ មានទៅពិបាកអី ធម្មតា មានទៅយើងណា មានគេគ្រប់គ្រងដែរ ។

គន្ធី ៖ អ្នកណាគេនៅពីលើមីងដែរ?

ភី ៖ មានប្រធាននារីគេ ស្រុកគេ ដូចយឿន ពីលើយើង យើងគ្រាន់តែផ្នែកមួយ ។

គន្ធី ៖ ចឹងមីងដូចថាមីងគ្រប់គ្រងដល់ស្រុកចឹង ដូចថាចាត់ចែងធ្វើការងាររបៀបម៉េចទៅ ធ្វើការ ងាររបៀបម៉េចទៅ មីងចូលដល់រាប់ពាន់យើងមានតែបែងចែកជាក្រុមទៀត?

ភី ៖ អាក្រុមមានអី ដល់ហើយយើងប្រាប់ទៅ ដូចថាក្រុមណាៗ យើងធ្វើតាមក្រុម វាមាន មេក្រុមគេ ។

គន្ធី ៖ មានការងារខ្វះបន្ទាន់ទេមីង នៅក្នុងពេលធ្វើការងារប៉ុន្មានឆ្នាំ ត្រូវតែធ្វើអីចឹង?

ភី ៖ ទេ! ចាំមិនបាន កាលនឹងវាមាន មិនចាំបាន ។

គន្ធី ៖ មានម៉េចទៅមីង ថាបន្ទាន់?

ភី ៖ ថាវាចាំមិនបានរឿងនឹងការងារ បន្ទាន់ការងារ ដឹងដែនការឲ្យធ្វើចឹងទៅ ហើយម៉ាកន្លែង ទៅម៉ាកន្លែងទៀតចឹងទៅ ។

គន្ធី ៖ ចុះមីងនៅក្នុងភូមិមីងដូចថាតាំងពីដូចថាយើងនៅចឹង មានអ្នកភូមិគេផ្សេងៗនៅក្នុងភូមិ មីងអីដែរចឹង មានហេតុការណ៍ដូចថារឿងមួយដូចថាល្បិតគ្នា ដូចគេបង្ខំឲ្យការភូមិនេះ ចេះចុះ មានដែលឮ?

ភី ៖ អត់ ។

គន្ធី ៖ អត់ដែលមានរឿងអី?

ភី ៖ អឺ!

គន្ធី ៖ ហើយកាលនឹងចុះម៉េចពេលនឹង មានរឿងជាមួយវៀតណាម?

ភី ៖ អត់ដឹងដែរ អ្នកណាទៅដឹងខាងផ្នែកឯកទេស រឿងរបស់គេ ដឹងជាដែនការម៉េចគេហៅ ថាអាយើងមិនដឹងរឿងស៊ីជម្រៅ រឿងប្រាប់ថាដែនការធំៗខ្ញុំមិនដឹងទេ ខ្ញុំដឹងរឿងដឹក ប្រឡាយតែមួយមុខទេ ។

គន្ធី ៖ ចឹងខាងមីងអត់មាននេះ មីងមានដឹងថាគេរើសបញ្ជូន ដូចថាបញ្ជូនកងទ័ពអីចឹង ដូចថា បញ្ជូនកងទ័ពឲ្យធ្វើប្រយុទ្ធជាមួយវៀតណាម នៅក្នុងភូមិយើងមានទេ?

ភី ៖ មាន នៅផ្នែកខាងប្រុសៗខ្ញុំម៉េចដឹង បើចេះមានដូចថា ឥឡូវកាលនឹងគេមិនមាននារី ស្មាក់ការគេ យើងបញ្ជូនទៅចាំសែងពួកកងទ័ពត្រូវរបួសអី យកមកពេទ្យមកអីអានឹង មាន គេឲ្យយើងរើសពីកងចល័តទៅហើយណា ។ ដល់នេះយើងបញ្ជូនទៅ អ្នកណាស្ម័គ្រ ចិត្តទៅៗ លើកឈ្មោះឲ្យគេទៅ ។

គន្ធី ៖ ទៅប្រយុទ្ធជាមួយវៀតណាម គេគ្រាន់តែជួយ?

ភី ៖ ស្រីៗនឹង ទៅប្រយុទ្ធស្អីវា គ្រាន់ថាកងទ័ពនឹងគេបាញ់គ្នា អ្នកណាត្រូវរបួសចឹងទៅ គេ សែងមកបន្តគ្នា គេដាក់មកតាមថ្នាក់ៗ ។

គន្ធី ៖ អត់មានទ័ពស្រីៗ?

ភី ៖ គ្មានទេ ។

គន្ធី ៖ ចុះមីងថាមាននិរសាមិញ ឈ្មោះអីខ្លះ?

ភី ៖ ឈ្មោះវាងាប់អស់ហើយ និរសាស្អី គ្រាន់ថាក្មេង នៅជាមួយធ្វើការចឹង ដូចថាគេថា ឥឡូវទៅយកសំបុត្រឲ្យពីណាចឹង ទៅហៅពួកអ្នកធ្វើការចឹង ឯងយកសំបុត្រទៅនេះ ទៅ នោះវាមិនមាននិរសាផ្ទាល់ខ្លួនសម្រាប់បម្រើសម្រាប់អីដូចនេះទេ ។ ដូចថាចង់ ឧបមាថា ជួនណាពេទ្យនៅតាមកងចល័តចឹងទៅ យើងប្រាប់ឲ្យពេទ្យនឹងទៅចឹងទៅ វាមាននិរសា អី គ្រាន់តែថានិរសានឹងច្រើនអ្នកនាំសំបុត្រនាំអី មិនមាននិរសាផ្ទាល់ខ្លួនអីឲ្យហឹក ។

គន្ធី ៖ ពួកគាត់ឈ្មោះអីដែរ និរសាក្នុងក្រុមទាំងអស់នឹង មីងចាំ?

ភី ៖ ចាំបានក្មេងៗតូចៗ ឈ្មោះមីរឿននោះ មិនដឹងងាប់រស់ទេ អាបូនោះ ដឹងថាងាប់ហើយ

គន្ធី ៖ ហើយស្លាប់ដោយសារអីដែរ បូនឹងមីង?

ភី ៖ ងាប់មកពីវាមានប្ដីមានអីណាទៅជិះរ៉ឺម៉ក់ ជិះអីធ្លាក់លើរ៉ឺម៉ក់ ដើរជួបដែរ ប៉ុន្ដែថ្ងៃមួយ ...ទៅវត្តតាអូរនឹង ព្រួសួរបងវានិយាយសួរថាបូម៉េចបានស្លាប់ បងវាថាធ្លាក់ពីលើរ៉ឺម៉ក ប្រហែលប៉ុន្មានថ្ងៃមុនបានដឹង ជួបគេក៏ខ្ញុំមិនស្គាល់គេ ។ ដល់ហើយគេស្គាល់គេសួរ ចេះតែ សួរគេទៅ ។

គន្ធី ៖ ចុះរឿងនឹងនៅណាដែរ?

ភី ៖ ដឹងនៅណាទេ នៅស្រុកគេនោះ ។

គន្ធី ៖ ស្រុកណាវិញ?

ភី : ច្រើនពីត្រាំកក់មកនឹង វាគ្មានឯណាទេ អ្នកមកធ្វើការកន្លែងនឹង ។

គន្ធី : ចុះមីងរឿងទៅក្រោយតិច មីងថាធ្វើការនៅយាយបូ ស្គាល់គាត់រៀងច្បាស់ដែរចឹង កាលមីងធ្វើការមុនមកភូមិវិញនឹង មីងនៅធ្វើជាមួយតំបន់ គណៈតំបន់ មីងនៅធ្វើអីដែរ?

ភី : អត់មាននៅតំបន់ ។

គន្ធី : មីងថាធ្វើការនៅជាមួយពួកអង្គភាពគេ ចឹងមុននឹង?

ភី : អង្គភាពនឹង ក៏មិនដែលនៅផ្នែកដល់តំបន់ ។

គន្ធី : តែមុននឹងមីងមានប្រសាសន៍ថា មីងស្គាល់គាត់រៀងច្បាស់ដែរ?

ភី : ស្គាល់ច្បាស់ តែនៅក្នុងស្រុកទេ មិនមាននៅតំបន់ទេ ។

គន្ធី : នៅស្រុកនឹងចឹង?

ភី : តំបន់ កាលនឹងគេសំដៅទៅខេត្ត ។

គន្ធី : មីងធ្លាប់នៅជាមួយយាយបូ តាតុំអី?

ភី : នៅៗ ។

គន្ធី : រស់នៅជាមួយគាត់ម៉ង?

ភី : ចាស៎! នៅ ។

គន្ធី : ធ្វើអីដែរ មីងដល់ពេលមីងនៅជាមួយគាត់?

ភី : ធ្វើអី ដាំបាយដាំអី រកអុស រកអីដុតចឹងទៅ មានទៅធ្វើអី កិនអង្ករ បុកអង្ករ ។

គន្ធី : ធ្វើការជាមួយគាត់ប្រហែលជារយៈពេលប៉ុន្មានដែរ?

ភី : ចាំទេ ប្អូនអើយ ។

គន្ធី : នៅជាមួយគាត់ទាំងប៉ុន្មាននាក់ដែរ មីងនៅជាមួយពីណាគេ?

ភី : នៅគ្នាច្រើន ម៉ាអង្គភាពគេនឹង នៅច្រើនគ្នា ខ្ញុំចាំមិនបាន ។

គន្ធី : ជាមួយតាតុំ ជាមួយយាយបូ រស់នៅជាមួយគ្នាម៉ង?

ភី : ចា៎! រស់នៅជាមួយ ។

គន្ធី : រស់នៅហូបបាយអី?

ភី : ហូបបាយអីនឹងគ្នា ។

គន្ធី : ហើយកាលនឹងមីងដឹងការងារគាត់ធ្វើអីខ្លះ តាតុំ យាយបូ?

ភី : មិនដឹងគាត់ធ្វើអី មិនដឹង ឮតែគេថាគាត់គណៈស្រុកៗចឹង មិនដឹង ។

គន្ធី ៖ កាលមីងនៅជាមួយគាត់ៗ មានចាត់ចែងការងារម៉េចខ្លះ?

ភី ៖ ទេ! ចាត់ចែង ការងារគាត់ ហ៎!ណាត្រូវដូចថានៅក្នុងអង្គភាពនឹង អ្នកណាត្បាញៗទៅ អាណាចិញ្ចឹមនាងៗទៅ អាណាធ្វើអីធ្វើទៅ ។ ចិញ្ចឹមនាង ត្បាញ ដាំដំណាំធម្មតា នៅចឹងទៅបាន ។

គន្ធី ៖ ចុះការងារពួកគាត់នោះ?

ភី ៖ ការងារពួកគាត់នឹង អ្នកណាទៅដឹងការងារពួកគាត់ៗ នៅស្ងៀម ម៉េចខ្ញុំប្រាប់ថាជំនាន់នឹងជំនាន់គេលាក់ការណ៍ គេរៀងការងារអីក្រៅពីតែគេមិនឲ្យយើងដឹងទេ ។

គន្ធី ៖ ចុះមីងនៅជាមួយគ្នា នៅក្នុងអង្គភាពនឹងប៉ុន្មានដែរ មីងរយៈពេលប៉ុន្មាន?

ភី ៖ យូរដែរ ប៉ុនមិនដឹងរយៈពេលប៉ុន្មាន យូរ ។

គន្ធី ៖ ប្រហែលជាប៉ុន្មាន មុននឹងបែកភ្នំពេញ?

ភី ៖ មិនដឹងប៉ុន្មានទេ ដល់ចប់ ។

គន្ធី ៖ ចូលឆ្នាំទេ?

ភី ៖ ចូលឆ្នាំ មកដល់នឹង ។

គន្ធី ៖ រយៈពេលម៉ាឆ្នាំ?

ភី ៖ ដឹងប៉ុន្មានទេ ពេញដីនៅនេះនោះខ្ញុំចាំមិនបានទេ ដូចថាខ្ញុំមិនយកចិត្តទុកដាក់ វាដូចថាវាគ្មានដឹងថ្ងៃត្រូវសួរនាំអីចឹង វាមិនចាំទុក ។

គន្ធី ៖ អត់អីទេមីង ចាំក៏ចាំទៅ ។ ចឹងមីងធ្វើការជាមួយគ្នាចឹង ក្រែងថានៅជាប់លាប់ជាមួយគាត់ចឹង ការងារគាត់អត់មាននេះ ដូចថាទាក់ទងគ្នាចឹង មានដឹងអីខ្លះ?

ភី ៖ អត់ដឹងទេ ។

គន្ធី ៖ យាយបូ?

ភី ៖ គ្មានដឹងអី ។

គន្ធី ៖ និយាយចឹងមីង មាននៅសល់ឯកសារអីពីរបបនឹងមក រូបថតអនុស្សាវរីយ៍អី?

ភី ៖ អត់មានទេ មិនដែលមានថតទេ ជំនាន់នឹងគ្មានស្គាល់រូបថតម៉េចទេ ។

គន្ធី ៖ ចុះឯកសារអី ដូចជាឯកសារពេទ្យ ឯកសារ?

ភី ៖ គ្មានៗ ស្អីក៏មិននៅដែរ ចោលទៅដូចថារបស់របរអីសូម្បីតែអំបិល សូម្បីតែចានឆ្នាំងដែលត្រូវនេះចោល គេថាភូមិផុង នៅបរសេដ្ឋ កាត់ក្អកចោលទាំងអស់នឹង ។

គន្ធី ៖ មានអីខ្លះទៅ មីងសប្រាប់យកឯកសារទៅនឹង?

ភី ៖ មានអីអាសៀវភៅធ្វើបញ្ជីចំនួន ការចំនាយនារី ការចំនាយហូបចុកអី វាគ្មានស្អីឯកសារអីទេ ហើយនឹង ចានឆ្នាំងអីនឹងចោលនៅនឹង សៀវភៅធម្មតា ។

គន្ធី ៖ អត់មានឯកសារអីនៅសល់ដល់ឥឡូវ ឯកសារ ក្រដាសតិចតួច សំបុត្រស្អីដែលមីងផ្ញើតាមនិរសារអី?

ភី ៖ អឺ! គ្មានសំបុត្រស្អីទេ ខ្ញុំគ្មានសំបុត្រស្អីផ្ញើបានឲ្យ ។

គន្ធី ៖ បឹងមីងអរគុណមីងច្រើន ។ ពួកខ្ញុំអស់សំនួរហើយ ។

ភី ៖ ចា៎!

«ចប់»